រួមគ្នា
យើងជា IMPERIAL BRANDS

IMPERIAL BRANDS

ក្រមប្រតិបត្តិរបស់យើង

ខែកញ្ញា ឆ្នាំ 2024

តារាង នៃ
មាតិកា

- គោលបំណង ចក្ខុវិស័យ និងអាកប្បកិរិយា របស់យើង
- មិត្តរួមការងារជាទីគោរព
- សេចក្តីផ្តើម
- ការសម្រេចចិត្តប្រកបដោយក្រមសីលធម៌
- រាយការណ៍ពីអ្វីដែលមិនត្រឹមត្រូវ
- អ្នកប្រើប្រាស់របស់យើង
- មនុស្សរបស់យើង
- ទ្រព្យសម្បត្តិ និងកេរ្តិ៍ឈ្មោះក្រុមហ៊ុនរបស់យើង
- សុចរិតភាពអាជីវកម្មរបស់យើង
- បរិស្ថាន និងសង្គម
- សទ្ធានុក្រម
- គោលការណ៍ និងធនធានផ្ទៃក្នុង

គោលបំណង ចក្ខុវិស័យ និងអាកប្បកិរិយារបស់យើង

គោលបំណងរបស់យើង

"បង្កើតផ្លូវទៅកាន់អនាគតដែលមានសុខភាពល្អសម្រាប់ពេលវេលាសម្រាក និងរីករាយ"។

ចក្ខុវិស័យរបស់យើង

"ដើម្បីកសាងអាជីវកម្មប្រកួតប្រជែងដ៏រឹងមាំមួយ ដែលដំណើរការដោយការទទួលខុសត្រូវ ការផ្តោត និងជម្រើស។"

អាកប្បកិរិយារបស់យើង

"អាកប្បកិរិយារបស់យើងកំណត់ពីរបៀបដែលយើងគួរធ្វើសកម្មភាព ធ្វើការសម្រេចចិត្ត និងប្រព្រឹត្តចំពោះគ្នាទៅវិញទៅមក។"

អាកប្បកិរិយា របស់យើង

ចាប់ផ្ដើមជាមួយ នឹង **អ្នកប្រើប្រាស់**

- អ្វីគ្រប់យ៉ាងដែលយើងធ្វើគឺចាប់ផ្ដើមដោយការគិតគូរអំពីអ្នកប្រើប្រាស់
- ធ្វើឱ្យវាជាអាជីវកម្មរបស់អ្នកដោយត្រូវយល់ពីអ្នកប្រើប្រាស់
- ធ្វើឱ្យមានភាពម៉ត់ចត់ចំពោះជម្រើសដែលអ្នកធ្វើ - ចង់ដឹងចង់ឃើញ សួរសំណួរ ប្រើការពិត និងទិន្នន័យ ស្វែងរកទស្សនៈផ្សេងៗដើម្បីសាកល្បងលើគំនិតរបស់អ្នក។
- រួមបញ្ចូលទិន្នន័យ និងការយល់ដឹង ក៏ដូចជាសភាវគតិ និងបទពិសោធន៍របស់អ្នកដើម្បីធ្វើការសម្រេចចិត្ត
- ផ្ដល់គុណភាពនៅក្នុងការងារដែលអ្នកធ្វើ

ការពង្រឹងផ្នត់គំនិត

អ្វីគ្រប់យ៉ាងដែលយើងធ្វើគឺចាប់ផ្ដើមពីអ្នកប្រើប្រាស់ - យើង នៅទីនេះ គឺដោយសារតែពួកគេ

ការស្គាល់អ្នកប្រើប្រាស់របស់យើងគឺជាគន្លឹះដើម្បីដោះសោភាពជោគជ័យនាពេលអនាគតរបស់យើង

ការសម្រេចចិត្តល្អគឺធ្វើឡើងដោយការរួមបញ្ចូលទិន្នន័យ ការយល់ដឹង និងបទពិសោធន៍



សហការ **ដោយមានគោលបំណងច្បាស់លាស់**

- ចែករំលែកចំណេះដឹង និងបទពិសោធន៍របស់អ្នកជាមួយអ្នកដទៃ
- ស្ដាប់ និងគោរពជំនាញរបស់មិត្តរួមការងាររបស់អ្នក
- មានឥទ្ធិពល មិនមែនបញ្ជានោះទេ
- ទុកចិត្តអ្នកដទៃ - អ្នកមិនចាំបាច់គ្រប់គ្រងអ្វីគ្រប់យ៉ាងទេ
- ធ្វើឱ្យមានតុល្យភាពរបៀបវារៈក្នុងតំបន់ជាមួយនឹងតម្រូវការ IMB (ត្រូវគិតគូរអំពីគោលដៅធំជារួម)
- ប្រកួតប្រជែងនៅខាងក្រៅ មិនមែនខាងក្នុងទេ

ការពង្រឹងផ្នត់គំនិត

វាជាផ្នែកមួយនៃការងាររបស់ខ្ញុំក្នុងការជួយអ្នកដទៃឱ្យទទួលបានជោគជ័យ

ខ្ញុំមិនចាំបាច់គ្រប់គ្រងអ្វីៗទាំងអស់ឡើយ

ការធ្វើការដោយមានការសហការជាមួយអ្នកដទៃនឹងផ្ដល់លទ្ធផលល្អប្រសើរសម្រាប់យើងទាំងអស់គ្នា



ទទួលខុសត្រូវ **ដោយភាពជឿជាក់**

- ត្រូវទទួលខុសត្រូវ និងឱ្យអ្នកដទៃទទួលខុសត្រូវផងដែរ
- សម្រេចឱ្យបាននូវអ្វីដែលអ្នកសន្យា
- បន្តផ្ដោតដោយឥតឈប់ឈរលើការងារអាទិភាពដែលបានព្រមព្រៀង
- បោះបង់ចោលអ្វីៗដែលមិនសំខាន់
- ចូលរួមក្នុងកិច្ចសន្ទនាបែបស្ថាបនា និងបើកចិត្តទទួលយកសំណួរអំពីទស្សនៈរបស់ខ្លួនឯង
- មិនត្រូវស្ដីបន្ទោសអ្នកដទៃ

ការពង្រឹងផ្នត់គំនិត

ការប្ដេជ្ញាចិត្តគឺជាការប្ដេជ្ញាចិត្ត

ត្រូវហ៊ានបញ្ចេញមតិ

នៅពេលដែលខ្ញុំធ្វើរឿងត្រឹមត្រូវ ការរួមចំណែករបស់ខ្ញុំនឹងត្រូវបានវិនិច្ឆ័យដោយយុត្តិធម៌

ស្មោះត្រង់ធ្វើជាខ្លួនឯង **រួមបញ្ចូលទាំងអស់គ្នា**

- ចំណាយពេលដើម្បីស្វាគមន៍អ្នកគ្រប់គ្នា
- ទទួលស្គាល់ និងដឹងគុណចំពោះអ្វីដែលអ្នកដទៃនាំមក
- ថែរក្សាគ្នាទៅវិញទៅមក - គ្មានករណីលើកលែង
- ចាត់ទុកថាភាពខុសគ្នាជាចំណុចខ្លាំងមួយ
- បង្ហាញភាពជាខ្លួនឯងពិតប្រាកដ
- នាំមកនូវភាពស្មោះត្រង់ ភាពបើកចំហ និងភាព| ឱនលំទោនក្នុងការសន្ទនាដ៏ស្វិតស្វាញ

ការពង្រឹងផ្នត់គំនិត

ខ្ញុំទទួលបានការស្វាគមន៍

ខ្ញុំទទួលបានការផ្ដល់តម្លៃ

ភាពចម្រុះកាន់តែច្រើន អាជីវកម្មរបស់យើងនឹងកាន់តែរឹងមាំ

កសាង **អនាគតរបស់យើង**

- គិតទុកជាមុនអំពីឱកាស និងបញ្ហាប្រឈមនាពេលអនាគត
- ដើរមួយជំហានទៅមុខមុនជានិច្ច
- ធ្វើតុល្យភាពរវាងលទ្ធផលការងាររយៈពេលវែង និងលទ្ធផលការងាររយៈពេលខ្លី
- ធ្វើការដើម្បីធ្វើឱ្យអ្វីៗកាន់តែប្រសើរឡើង
- ទទួលយកការផ្លាស់ប្ដូរ និងស្វាគមន៍ការច្នៃប្រឌិត - មានឆន្ទៈក្នុងការសាកល្បងអ្វីដែលថ្មី និងត្រៀមខ្លួនដើម្បីរៀនពីភាពបរាជ័យ

ការពង្រឹងផ្នត់គំនិត

ខ្ញុំជឿជាក់លើភាពជោគជ័យរបស់យើង

វាសំខាន់ណាស់ក្នុងការសាកល្បងអ្វីដែលថ្មី

ការរៀនពីភាពបរាជ័យ និងឧបសគ្គរបស់យើង គឺជាវិធីដែលយើងរៀនដើម្បីទទួលបានភាពជោគជ័យ

← ត្រឡប់ទៅទំព័រមាតិកា

មិត្តរួមការងារ ជាទីគោរព

ភាពជោគជ័យរបស់យើងបានមកដោយការទទួលខុសត្រូវលើអាជីវកម្ម រួមទាំងការទទួលខុសត្រូវរបស់និយោជិតម្នាក់ៗ។

ក្រមប្រតិបត្តិរបស់យើងគឺជាអ្នកនែនាំឱ្យយើងធ្វើរឿងត្រឹមត្រូវនៅ Imperial Brands ។

តាមវិធីជាក់ស្តែង ក្រមពិពណ៌នាអំពីរបៀបដែលយើងទាំងអស់គ្នាអាចគាំទ្រគោលបំណងរបស់យើងបានល្អបំផុត - បង្កើតផ្លូវទៅកាន់អនាគតដែលមានសុខភាពល្អសម្រាប់អ្នកពាក់ព័ន្ធទាំងអស់ - និងចក្ខុវិស័យរបស់យើងដើម្បីក្លាយជាអាជីវកម្មដែលដំណើរការដោយការទទួលខុសត្រូវ។

យើងម្នាក់ៗត្រូវចំណាយពេលដើម្បីស្វែងយល់អំពីក្រមដោយផ្តល់ឱ្យយើងនូវទំនុកចិត្តក្នុងការទទួលខុសត្រូវចំពោះរបៀបដែលយើងធ្វើការ និងធ្វើអាកប្បកិរិយា។

សូមអានក្រមដោយប្រុងប្រយ័ត្ន។ ពិភាក្សាជាមួយមិត្តរួមការងារ។ សួរអ្នកដឹកនាំក្រុម របស់អ្នក ឬសមាជិកណាមួយនៃក្រុមអ្នកដឹកនាំជាន់ខ្ពស់ ប្រសិនបើមានអ្វីដែលអ្នកមិនយល់។

តាមរយៈការកំណត់យ៉ាងច្បាស់នូវជំនឿ និងការរំពឹងទុករបស់យើង ក្រមជួយយើងធ្វើការសម្រេចចិត្តដោយសុចរិតភាពក្នុងរបៀបមួយដែលស្របគ្នានៅទូទាំងស្ថាប័នសកលលោករបស់យើងដោយមិនគិតពីតួនាទី ឬទីតាំង។

សូមបញ្ចេញមតិ ប្រសិនបើអ្នកសង្កេតឃើញ ឬសង្ស័យអាកប្បកិរិយាណាមួយដែលមិនសមស្របនឹងក្រម។ ការសម្ងាត់របស់អ្នកនឹងត្រូវបានរក្សាទុក ហើយយើងនឹងមិនអត់ឱនចំពោះការតបតសងសឹកទៅលើការរាយការណ៍ឬបញ្ចេញមតិរបស់អ្នកឡើយ។

ការធ្វើសកម្មភាពជាមួយនឹងស្តង់ដារខ្ពស់បំផុតនៃអាកប្បកិរិយាគឺជារឿងត្រឹមត្រូវដែលត្រូវធ្វើ និងជាវិធីដែលយើងនឹងបង្កើតឱ្យមានកំណើនប្រកបដោយនិរន្តរភាពក្នុងរយៈពេលវែង។

Stefan Bomhard
នាយកប្រតិបត្តិ

← ត្រឡប់ទៅទំព័រមាតិកា

សេចក្ដីនែនាំ
អំពីក្រមប្រតិបត្តិ

ក្រមប្រតិបត្តិរបស់យើងកំណត់ស្តង់ដារនៃអាកប្បកិរិយាដែលយើងរំពឹងពីអ្នកគ្រប់គ្នាដែលធ្វើការនៅImperial Brands ។

ក្រមនេះផ្តល់នូវក្របខណ្ឌមួយដើម្បីធានាថាយើងសម្រេចបាននូវគោលដៅអាជីវកម្មរបស់យើងដោយសុចរិតភាព។

ក្រមនេះអនុវត្តចំពោះមនុស្សគ្រប់គ្នានៅក្រុមហ៊ុន Imperial Brands រួមទាំងនាយក អ្នកគ្រប់គ្រង និយោជិត កម្មករ និយោជិតបណ្តោះអាសន្ន និងក្រុមហ៊ុនបុត្រសម្ព័ន្ធដែលស្ថិតក្រោមការគ្រប់គ្រងទាំងស្រុងរបស់យើង។

អ្នកមានទំនួលខុសត្រូវក្នុងការអាន និងស្វែងយល់អំពីក្រម និងបំពេញរាល់ការបណ្តុះបណ្តាលស្តីពីការអនុលោម និងកាតព្វកិច្ចដែលបានចាត់ឱ្យអ្នក។ ប្រសិនបើអ្នកមានសំណួរណាមួយអំពីការរំពឹងទុកដែលមានចែងក្នុងក្រមនេះ សូមនិយាយទៅកាន់ អ្នកដឹកនាំក្រុម របស់អ្នក អ្នកប្រឹក្សាផ្នែកច្បាប់ក្នុងតំបន់ ឬសមាជិកផ្នែកច្បាប់របស់ Group ។

អ្នកនឹងត្រូវបានស្នើសុំឱ្យបញ្ជាក់ពីការយល់ដឹងរបស់អ្នកអំពីក្រម ដែលជាផ្នែកនៃវគ្គបណ្តុះបណ្តាលជាប្រចាំ ដែលធ្វើឡើងលើប្រធានបទនៃក្រម និងក្រម។



សេចក្ដីនែនាំ អំពីក្រមប្រតិបត្តិ

ទំនួលខុសត្រូវរបស់ អ្នកដឹកនាំក្រុម

ប្រសិនបើអ្នកជា អ្នកដឹកនាំក្រុម អ្នកមានទំនួលខុសត្រូវបន្ថែមនៅពេលនិយាយអំពីក្រម៖

- ស្វែងយល់ពីកាតព្វកិច្ចរបស់អ្នកក្នុងការគាំទ្រ និងអនុវត្តក្រម
- ស្វែងរកឱកាសដើម្បីចែករំលែក និងពន្យល់អំពីក្រម
- ធ្វើជាគំរូដោយធ្វើតាមក្រម និងធ្វើជាគំរូល្អសម្រាប់ក្រុមរបស់អ្នក និងមិត្តរួមការងារផ្សេងទៀត
- ត្រូវប្រាកដថាក្រុមរបស់អ្នកបានបញ្ចប់ការបណ្ដុះបណ្ដាលចាំបាច់ទាំងអស់ដែលទាក់ទងនឹងក្រម និងប្រធានបទនៃការអនុលោម
- លើកទឹកចិត្តឱ្យក្រុមរបស់អ្នកសួរសំណួរ លើកឡើងនូវកង្វល់ និងហ៊ាននិយាយប្រសិនបើមានអ្វីដែលមិនត្រឹមត្រូវ ហើយនៅពេលដែលពួកគេនិយាយ ចូរស្ដាប់ដោយយកចិត្តទុកដាក់ហើយចាត់វិធានការឱ្យបានសមរម្យ។

កត់សម្គាល់តួនាទីសំខាន់ដែលអ្នកមានក្នុងការធ្វើឱ្យមិត្តរួមការងារមានទំនុកចិត្តក្នុងការសុំជំនួយ និងមានអារម្មណ៍ថាមានសុវត្ថិភាពក្នុងការសម្រេចចិត្តពិបាកៗ នៅពេលដែលវាជារឿងត្រឹមត្រូវ។ ប្រសិនបើអ្នកត្រូវការការណែនាំ ឬដំបូន្មាន សូមស្វែងរកជំនួយពីអ្នកប្រឹក្សាផ្នែកច្បាប់ក្នុងតំបន់របស់អ្នក ឬផ្នែកច្បាប់របស់ Group ។

ការពង្រឹងការអនុវត្តក្រម

វិធីសាស្ត្រប្រកបដោយទំនួលខុសត្រូវរបស់យើងចំពោះអាជីវកម្មមានន័យថាការពង្រឹងការទទួលខុសត្រូវចំពោះស្តង់ដារដែលបានរំពឹងទុកនៃការអនុវត្តរបស់យើង។ បុគ្គលដែលពាក់ព័ន្ធនឹងការបំពានលើក្រមនឹងត្រូវទទួលរងនូវនីតិវិធីវិន័យដោយយុត្តិធម៌ យោងតាមគោលការណ៍វិន័យរបស់យើង។ ការបំពានច្បាប់ក៏អាចប្រឈមនឹងទណ្ឌកម្មផ្លូវច្បាប់ ឬការពិន័យផ្សេងៗផងដែរ។

ចុចទីនេះសម្រាប់ធនធានផ្ទៃក្នុង

ការសម្រេចចិត្ត ប្រកបដោយ ក្រមសីលធម៌

យើងម្នាក់ៗទទួលខុសត្រូវចំពោះការសម្រេចចិត្តដែលយើងធ្វើនៅក្នុងការងាររបស់យើង។
ពេលខ្លះការសម្រេចចិត្តត្រឹមត្រូវតាមច្បាប់ និងមានក្រមសីលធម៌គឺច្បាស់លាស់។ ពេលខ្លះទៀត ការសម្រេចចិត្តត្រឹមត្រូវគឺពិបាកក្នុងការកំណត់។ វាជារឿងសំខាន់ដែលយើងធ្វើការសម្រេចចិត្តដែលយើងអាចមានមោទនភាពជានិច្ច។

នៅពេលប្រឈមមុខនឹងការសម្រេចចិត្តពិបាក ឬសំណើមិនធម្មតា សូមសួរខ្លួនឯងនូវសំណួរទាំងនេះ៖

ស្តាប់ទៅដូចជាអ្នកប្រហែលជាត្រូវការជំនួយ៖

សុំការណែនាំពី **អ្នកដឹកនាំក្រុម អ្នកប្រឹក្សាផ្នែកច្បាប់ក្នុងតំបន់របស់អ្នក** ឬ **ផ្នែកច្បាប់របស់ Group**

ខ្ញុំមិនប្រាកដ...

តើវាស្របច្បាប់ទេ?

បាទ/ចាស

តើវាស្របនឹងក្រមគោលការណ៍ក្រុមហ៊ុន និងអាកប្បកិរិយារបស់យើងដែរឬទេ?

បាទ/ចាស

តើខ្ញុំយល់ពីហានិភ័យ និងផលវិបាកទេ?

បាទ/ចាស

តើខ្ញុំអាចបង្ហាញអំពីភាពត្រឹមត្រូវនៃសកម្មភាពរបស់ខ្ញុំចំពោះមិត្តរួមការងារបានទេ?

បាទ/ចាស

តើអ្នកដទៃនឹងគិតយ៉ាងណាប្រសិនបើពួកគេអានអំពីសកម្មភាពរបស់ខ្ញុំក្នុងព័ត៌មាន?

បាទ/ចាស

ប្រសិនបើចម្លើយចំពោះសំណួរទាំងអស់នេះគឺបាទ/ចាស វាប្រហែលជាមិនអីទេក្នុងការបន្ត។

ប្រសិនបើអ្នកនៅតែមានកង្វល់ សូមពិគ្រោះជាមួយ អ្នកដឹកនាំក្រុមរបស់អ្នក ឬអ្នកប្រឹក្សាផ្នែកច្បាប់ក្នុងតំបន់។

ទេ...

កុំបន្ត៖

ការឆ្លើយថាទេចំពោះសំណួរទាំងនោះមានន័យថាមានវាមានភាគរយខ្ពស់ដែលនេះគឺជាការសម្រេច ឬសំណើដែលមិនអាចទទួលយកបាន។
សុំការណែនាំពី **អ្នកដឹកនាំក្រុម អ្នកប្រឹក្សាផ្នែកច្បាប់ក្នុងតំបន់របស់អ្នក** ឬ **ផ្នែកច្បាប់របស់ Group**

រាយការណ៍ពីអ្វីដែលមិនត្រឹមត្រូវ

មានភាពក្លាហានក្នុងការ ប្រសិនបើអ្នកមានក្តីបារម្ភអំពីការប្រព្រឹត្តិខុសនៅក្រុមហ៊ុន Imperial Brands ។ ប្រសិនបើអ្នកសង្កេតឃើញការប្រព្រឹត្តដែលបំពានលើការរំពឹងទុកដែលមានចែងក្នុងក្រម ឬប្រសិនបើអ្នកត្រូវបានស្នើសុំឱ្យធ្វើអ្វីមួយដែលហាក់ដូចជាមិនសមស្របនឹងក្រមគោលការណ៍ក្រុមហ៊ុន ឬច្បាប់ យើងលើកទឹកចិត្តឱ្យអ្នករាយការណ៍។

មានវិធីជាច្រើនដើម្បីរាយការណ៍ពីការប្រព្រឹត្តខុស៖

- និយាយទៅកាន់ អ្នកដឹកនាំក្រុម របស់អ្នក ឬដៃគូអាជីវកម្ម People & Culture (P&C) ក្នុងតំបន់។ អ្នកក៏អាចទាក់ទង អ្នកប្រឹក្សាផ្នែកច្បាប់របស់ Group ដោយផ្ទាល់ប្រសិនបើអ្នកចង់។
- រាយការណ៍ពីកង្វល់របស់អ្នកដោយសម្ងាត់តាមរយៈវេទិកា Speaking Up អនឡាញដែលមានសុវត្ថិភាពរបស់យើង។ អ្នកអាចចូលប្រើប្រព័ន្ធពីកុំព្យូទ័ររបស់អ្នក ឬឧបករណ៍ចល័តដោយស្កេនកូដ QR នៅលើទំព័រនេះ ឬចូលទៅកាន់ **https://imperialbrands.whistleblowernetwork.net**។ របាយការណ៍របស់អ្នកអាចត្រូវបានដាក់បញ្ជូនដោយអនាមិក ប្រសិនបើត្រូវការ។

  នៅក្នុងប្រទេសមួយចំនួន អ្នកក៏អាចហៅទូរសព្ទទៅលេខទូរសព្ទក្នុងស្រុកដោយមិនគិតថ្លៃដើម្បីរាយការណ៍ពីកង្វល់បានផងដែរ។ ចូលប្រើបញ្ជីលេខទូរសព្ទ **នៅទីនេះ**។ បញ្ចូលលេខកូដ **25492** នៅពេលត្រូវបានសួរ។
- រាយការណ៍ពីកង្វល់របស់អ្នកជាលាយលក្ខណ៍អក្សរទៅកាន់៖
  Imperial Brands Plc, Attn: Speaking Up,
  121 Winterstoke Road, Bristol BS3 2LL UK |
  speakup@impbrands.com

  នៅអាមេរិកខាងជើង រាយការណ៍ទៅកាន់ ITG Brands តាមរយៈ៖
  ITG Brands Speaking Up,
  714 Green Valley Road, Greensboro, NC 27408 |
  ទូរសព្ទ៖ +1 866 447 6092
  https://secure.ethicspoint.com

ទោះយ៉ាងណាក៏ដោយ អ្នកជ្រើសរើសរាយការណ៍ របាយការណ៍របស់អ្នកនឹងត្រូវបានពិនិត្យ ហើយប្រសិនបើចាំបាច់ ត្រូវស៊ើបអង្កេត។

ចុចទីនេះសម្រាប់ធនធានផ្ទៃក្នុង

រាយការណ៍ពីអ្វីដែលមិនត្រឹមត្រូវ

យើងនឹងរក្សាការសម្ងាត់សម្រាប់អ្នកណាដែលហ៊ាន រាយការណ៍ហើយនឹងមិនអត់ឱនចំពោះទម្រង់ណាមួយនៃការសងសឹក ឬការរើសអើងលើនរណាម្នាក់ដែលលើកឡើងពីក្តីបារម្ភ ឬចូលរួមក្នុងការស៊ើបអង្កេតនោះទេ។ អាកប្បកិរិយាសងសឹកអាចនាំឱ្យមានវិធានការវិន័យ និងអាចឈានទៅដល់ការបណ្តេញចេញ។

ឆានែល Speaking Up របស់យើងមានសម្រាប់និយោជិត Imperial និងកម្មករនិយោជិតបណ្តោះអាសន្ន ក៏ដូចជាអ្នកផ្គត់ផ្គង់ និងដៃគូអាជីវកម្មខាងក្រៅ និងសហគមន៍ដែលយើងធ្វើការជាមួយ។ អ្នកត្រូវបានលើកទឹកចិត្តឱ្យផ្សព្វផ្សាយឆានែល Speaking Up របស់យើងទៅកាន់នរណាម្នាក់ដែលធ្វើការជាមួយ ឬក្នុងនាម Imperial Brands ។

ការលើកឡើងនូវបណ្តឹងសារទុក្ខ

បណ្តឹងទុក្ខរបស់និយោជិត ដូចជាបញ្ហាដែលទាក់ទងនឹងវឌ្ឍនភាពការងាររបស់អ្នក លក្ខខណ្ឌការងារ ឬការមិនចុះសម្រុងជាមួយមិត្តរួមការងារ ត្រូវបានដោះស្រាយខុសពីការរំលោភលើក្រម។

ដើម្បីដោះស្រាយបណ្តឹងសារទុក្ខ អ្នកគួរតែមានគោលដៅដោះស្រាយបញ្ហាក្រៅផ្លូវការជាមុនសិន ដោយនិយាយទៅកាន់ អ្នកដឹកនាំក្រុម របស់អ្នក។ ប្រសិនបើអ្នកមានអារម្មណ៍ថាមិនអាចធ្វើដូច្នេះបាន សូមនិយាយទៅកាន់អ្នកគ្រប់គ្រងជាន់ខ្ពស់ ឬដៃគូអាជីវកម្ម P&C ក្នុងតំបន់របស់អ្នក។

ប្រសិនបើបណ្តឹងសារទុក្ខរបស់អ្នកមិនអាចដោះស្រាយក្រៅផ្លូវការបានទេ អ្នកអាចលើកករណីជាផ្លូវការដោយអនុលោមតាមនីតិវិធីបណ្តឹងសារទុក្ខក្នុងតំបន់របស់អ្នក។ និយាយជាមួយដៃគូអាជីវកម្ម P&C របស់អ្នកសម្រាប់ព័ត៌មានបន្ថែម។

Imperial Brands នឹងមិនអត់ឱនចំពោះទម្រង់នៃការសងសឹក ឬការរើសអើងចំពោះនរណាម្នាក់ដែលរាយការណ៍អំពីបណ្តឹងសារទុក្ខនោះទេ។

សូមមើលផងដែរ៖ គោលការណ៍ Speaking Up

ចុចទីនេះសម្រាប់ធនធានផ្ទៃក្នុង

អ្នកប្រើប្រាស់របស់យើង

យើងបានដាក់វាជាអាជីវកម្មរបស់យើងដោយត្រូវស្វែងយល់ពីអ្នកប្រើប្រាស់ជាមនុស្សពេញវ័យ ដោយរួមបញ្ចូលទិន្នន័យ និងការយល់ដឹងរួមជាមួយនឹងបទពិសោធដ៏ស៊ីជម្រៅរបស់យើង។

យើងយល់ពីកង្វល់របស់សង្គមអំពីហានិភ័យសុខភាពនៃការជក់បារី និងទទួលស្គាល់តួនាទីរបស់យើងក្នុងការជួយកាត់បន្ថយគ្រោះថ្នាក់ តាមរយៈការអភិវឌ្ឍប្រកបដោយការទទួលខុសត្រូវ និងការធ្វើទីផ្សារនៃផលិតផលដែលមានសក្តានុពលក្នុងការកាត់បន្ថយហានិភ័យដូចជា បារីអេឡិចត្រូនិច(វ៉េប) បារីពាក់កណ្តាលអេឡិចត្រូនិច(ហីតទីត តូបាក់គូ) និងថង់ជាតិនីកូទីន។

12 ការធ្វើទីផ្សារប្រកបដោយទំនួលខុសត្រូវ
13 គុណភាពជំរុញគុណតម្លៃ
14 សុចរិតភាពក្នុងវិទ្យាសាស្ត្រ

“គោលបំណងរបស់យើងគឺដើម្បីបម្រើតម្រូវការរបស់មនុស្សពេញវ័យដែលបានធ្វើការជ្រើសរើសផ្អែកលើព័ត៌មានពាក់ព័ន្ធក្នុងការប្រើប្រាស់ផលិតផលរបស់យើង។”

← ត្រឡប់ទៅទំព័រមាតិកា

ការធ្វើទីផ្សារប្រកបដោយទំនួលខុសត្រូវ

យើងប្ដេជ្ញាចិត្តចំពោះការធ្វើទីផ្សារ និងការផ្សាយពាណិជ្ជកម្មប្រកបដោយទំនួលខុសត្រូវនៃផលិតផលរបស់យើង ស្របតាមច្បាប់ ក្រមនៃការអនុវត្ត និងកិច្ចព្រមព្រៀងស្ម័គ្រចិត្តនៃប្រទេសដែលយើងប្រតិបត្តិការ។ យើងអនុវត្តគោលការណ៍នៃការធ្វើទីផ្សាររបស់យើងចំពោះរាល់សកម្មភាពផ្សាយពាណិជ្ជកម្ម និងផ្សព្វផ្សាយ ហើយតម្រូវឱ្យដៃគូអាជីវកម្មខាងក្រៅរបស់យើងធ្វើដូចគ្នា។



- **ផ្សាយពាណិជ្ជកម្ម និងធ្វើទីផ្សារផលិតផលរបស់យើងចំពោះតែអ្នកជក់បារីពេញវ័យ ឬអ្នកប្រើប្រាស់ពេញវ័យប៉ុណ្ណោះលើផលិតផលនីកូទីន។**
- **ផ្ដល់ព័ត៌មានច្បាស់លាស់ និងត្រឹមត្រូវអំពីផលិតផលរបស់យើង និងហានិភ័យរបស់វា**
- **ធានាថារាល់ការអះអាងនៃផលិតផលរបស់យើងគឺជាការពិត និងអាចបញ្ជាក់ថាត្រឹមត្រូវ**
- **កុំប្រើរូបភាព ឬខ្លឹមសារក្នុងគោលបំណងទាក់ទាញយុវជន**

ទាញចុចទីនេះសម្រាប់ធនធានផ្ទៃក្នុង

គោលការណ៍នៃការធ្វើទីផ្សារ

1. យើង**ទាក់ទាញតែអ្នកប្រើប្រាស់ពេញវ័យនៃផលិតផល**ថ្នាំជក់ និងនីកូទីនប៉ុណ្ណោះ
2. ការធ្វើទីផ្សាររបស់យើង**គឺមានភាពស្មោះត្រង់ និងតម្លាភាព**
3. យើងផ្ដល់ឱ្យអ្នកប្រើប្រាស់របស់យើងនូវព័ត៌មានដែលពួកគេត្រូវការដើម្បី**ធ្វើការជ្រើសរើសផ្អែកលើព័ត៌មានដែលពាក់ព័ន្ធ។**
4. យើងនឹង**មិនលើកទឹកចិត្តមនុស្សឱ្យចាប់ផ្ដើមជក់បារី** ឬអ្នកមិនជក់បារីឱ្យប្រើផលិតផលនីកូទីននោះទេ ហើយនឹងមិនបំបាក់ទឹកចិត្តអ្នកប្រើប្រាស់ផលិតផលរបស់យើងឱ្យបញ្ឈប់ការឈប់ប្រើផងដែរ។
5. យើង**អនុវត្តតាមច្បាប់ក្នុងតំបន់ ក្រមនៃការអនុវត្ត និងកិច្ចព្រមព្រៀងស្ម័គ្រចិត្ត**ដែលគ្រប់គ្រងការផ្សាយពាណិជ្ជកម្ម ការផ្សព្វផ្សាយ និងការលក់ផលិតផលរបស់យើង

គុណភាពជំរុញគុណតម្លៃ

យើងមិនងាករេក្នុងការប្តេជ្ញាចិត្តរបស់យើងក្នុងការលើកកម្ពស់វប្បធម៌នៃគុណភាព និងបន្តស្វែងរកការកែលម្អស្តង់ដារអាជីវកម្ម ដំណើរការ និងផលិតផលរបស់យើង ស្របតាមលក្ខខណ្ឌតម្រូវនៃបទប្បញ្ញត្តិ និងការរំពឹងទុករបស់អ្នកប្រើប្រាស់។ វិធីសាស្រ្តជាប្រព័ន្ធរបស់យើងចំពោះការគ្រប់គ្រងគុណភាពត្រូវបានទ្រទ្រង់ដោយគោលការណ៍សំខាន់ៗចំនួនបី៖
ធ្វើវាឱ្យបានត្រឹមត្រូវ រក្សាវាឱ្យបានត្រឹមត្រូវ ហើយ **ដោះស្រាយកំហុស**។



- **ធ្វើឱ្យខ្លួនអ្នកដឹងពីនីតិវិធីរបស់ក្រុមហ៊ុនសកល ឬក្នុងតំបន់ដែលអនុវត្តចំពោះការងាររបស់អ្នក**
- **ស្តាប់ និងធ្វើសកម្មភាពលើមតិកែលម្អរបស់អ្នកប្រើប្រាស់ ដោយប្រើប្រាស់ទិន្នន័យ ការយល់ដឹង និងបទពិសោធរបស់អ្នកដើម្បីធ្វើការសម្រេចចិត្ត**
- **កុំខកខានក្នុងការធ្វើសកម្មភាពលើសុវត្ថិភាពអ្នកប្រើប្រាស់ ឬបញ្ហាគុណភាព ហើយបន្តស្វែងរកការកែលម្អដំណើរការ សេវាកម្ម និងគុណភាពផលិតផលរបស់យើង**
- **ផ្តល់គុណភាពនៅក្នុងការងារដែលអ្នកធ្វើ តែងចាប់ផ្តើមពីអ្នកប្រើប្រាស់ជានិច្ច**

ចុចទីនេះសម្រាប់ធនធានផ្ទៃក្នុង

“ភាពជោគជ័យ និងកេរ្តិ៍ឈ្មោះរបស់យើងអាស្រ័យលើសមត្ថភាពរបស់យើងក្នុងការចែកចាយផលិតផលប្រកបដោយគុណភាពត្រឹមត្រូវ ដែលផ្តល់ឱ្យអ្នកប្រើប្រាស់ពេញវ័យនូវពេលវេលាសម្រាក និងរីករាយ”

← ត្រឡប់ទៅទំព័រមាតិកា

សុចរិតភាពក្នុងវិទ្យាសាស្ត្រ

យើងប្តេជ្ញាចិត្តក្នុងការរក្សាការគ្រប់គ្រងផលិតផល និងទំនួលខុសត្រូវសុខភាពរបស់យើងនៅគ្រប់ខ្សែសង្វាក់ផលិតផលទាំងស្រុងរបស់យើង រួមទាំងការវាយតម្លៃសក្តានុពលនៃផលិតផលជំនាន់ក្រោយ ដើម្បីរួមចំណែកដ៏មានអត្ថន័យដល់សុខភាពសាធារណៈ។ យើងធ្វើដូចនេះដោយធ្វើការវាយតម្លៃសុវត្ថិភាពផលិតផលយ៉ាងទូលំទូលាយនៃផលិតផលរបស់យើងពេញមួយវដ្តជីវិតរបស់វា និងវាយតម្លៃសក្តានុពលកាត់បន្ថយគ្រោះថ្នាក់ថ្នាំជក់នៃផលិតផលជំនាន់ក្រោយ។



- អនុវត្តតាមក្របខណ្ឌវាយតម្លៃវិទ្យាសាស្ត្រពហុដំណាក់កាល និងពហុវិន័យរបស់យើងសម្រាប់ការវាយតម្លៃសុវត្ថិភាពផលិតផល និងសម្រាប់ការវាយតម្លៃសក្តានុពលកាត់បន្ថយគ្រោះថ្នាក់ថ្នាំជក់នៃផលិតផលជំនាន់ក្រោយ
- មានតម្លាភាពអំពីការច្នៃប្រឌិត ការរកឃើញនៃការស្រាវជ្រាវ និងវិធីសាស្ត្ររបស់យើង ដែលអាចត្រូវបានរកឃើញនៅលើផ្នែកបណ្ណសារស្រាវជ្រាវនៃគេហទំព័ររបស់យើង នៅទីនេះ
- យើងធ្វើការតែជាមួយដៃគូស្រាវជ្រាវ និងការបង្កើតថ្មីដែលបានជ្រើសរើសដោយប្រុងប្រយ័ត្នប៉ុណ្ណោះ ដែលប្តេជ្ញាអនុវត្តស្តង់ដារខ្ពស់ជាប់លាប់នៃការអនុវត្តប្រកបដោយសីលធម៌ និងការប្រព្រឹត្តិតាមបែបវិទ្យាសាស្ត្រ
- យើងអភិវឌ្ឍតែផលិតផលសម្រាប់អ្នកជក់បារីពេញវ័យ និងអ្នកប្រើប្រាស់ពេញវ័យនៃផលិតផលនីកូទីនប៉ុណ្ណោះ

> យើងធ្វើការនៅក្នុងស្តង់ដារវិទ្យាសាស្ត្រ បទប្បញ្ញត្តិ និងក្របខណ្ឌដែលបានបង្កើតឡើង និងដើម្បីការអនុវត្តល្អបំផុតក្នុងឧស្សាហកម្ម

ចុចទីនេះសម្រាប់ធនធានផ្ទៃក្នុង

មនុស្សរបស់យើង

ការអភិវឌ្ឍជំនាញ និងសក្តានុពលរបស់សហសេវិករបស់ Imperial Brands គឺមានសារៈសំខាន់ចំពោះមហិច្ឆតារបស់យើង។

យើងទទួលស្គាល់បុគ្គលម្នាក់ៗក្នុងភាពជាខ្លួនឯងរបស់ពួកគេ ហើយបង្ហាញពីការគោរពចំពោះតម្លៃដែលមនុស្សម្នាក់ៗនាំយកមកដោយមិនគិតពីវប្បធម៌ ជំនឿ ឬរបៀបរស់នៅឡើយ។

16 ការលើកកម្ពស់ការគោរព ការប្រព្រឹត្តិចំពោះគ្នាដោយយុត្តិធម៌ ភាពចម្រុះ សមធម៌ និងបរិយាបន្ន

17 ការអភិវឌ្ឍទេពកោសល្យ

18 ការផ្តល់កន្លែងធ្វើការប្រកបដោយសុវត្ថិភាព សុខភាព និងការគាំទ្រ

19 ការគោរពសិទ្ធិមនុស្ស

“អាកប្បកិរិយាស្នូលរបស់យើងទ្រទ្រង់ដល់វប្បធម៌ដែលជំរុញដោយការអនុវត្ត និងមានបរិយាបន្នដែលយើងកំពុងសាងសង់នៅ Imperial”

← ត្រឡប់ទៅទំព័រមាតិកា

ការលើកកម្ពស់ការគោរព ការប្រព្រឹត្តិចំពោះគ្នាដោយយុត្តិធម៌ ភាពចម្រុះ សមធម៌ និងបរិយាបន្ន

យើងមានគោលដៅបង្កើតស្ថាប័នចម្រុះ និងមានបរិយាបន្នដ៏ពិតប្រាកដដែលល្បីល្បាញសម្រាប់ការអបអរភាពខុសគ្នា ដែលធ្វើឱ្យនិយោជិតរបស់យើងមានអារម្មណ៍ថាពួកគេចូលចំណោមគេចុះ និងអាចជាខ្លួនឯងពិតប្រាកដ។ យើងគោរព ទទួលស្គាល់ និងឱ្យតម្លៃលើភាពចម្រុះនៃអ្នកប្រើប្រាស់របស់យើង និងឆ្លុះបញ្ចាំងពីសហគមន៍ដែលយើងប្រតិបត្តិការ។

កន្លែងធ្វើការរបស់យើងគឺជាកន្លែងមួយដែលនិយោជិតត្រូវបានប្រព្រឹត្តចំពោះគ្នាដោយសេចក្តីថ្លៃថ្នូរ សមធម៌ និងការគោរព។ យើងព្យាយាមឆ្លើយតបទៅនឹងបណ្តឹងសារទុក្ខរបស់និយោជិតឱ្យបានជាប់លាប់ យុត្តិធម៌ និងទាន់ពេលវេលា។ យើងនឹងមិនអត់ឱនចំពោះអំពើហិង្សា ការបង្ខិតបង្ខំ ការបំភិតបំភ័យ ការសម្លុត ការយាយីការបៀតបៀនផ្លូវភេទ ការរើសអើង ឬការបង្ខូចកេរ្តិ៍ឈ្មោះផ្សេងទៀត ឬអាកប្បកិរិយាមិនរាប់បញ្ចូលដោយផ្អែកលើលក្ខណៈផ្ទាល់ខ្លួនឡើយ។



- **ត្រូវដឹងពីភាពលំអៀងដោយមិនដឹងខ្លួនរបស់អ្នក។ ទាំងនេះគឺជាជំនឿផ្សារភ្ជាប់និងបទពិសោធន៍កន្លងមកដែលលាក់កំបាំងទុកក្នុងចិត្តដែលយើងទាំងអស់គ្នាមាន ហើយមានឥទ្ធិពលដល់ការយល់ឃើញរបស់យើងចំពោះពិភពលោក**
- **ត្រូវចេះយល់ចិត្ត និងឆ្លៀតពេលស្វែងរក និងពិចារណាពីទស្សនៈ និងវិធីនៃការគិតផ្សេងគ្នា**
- **សូមចងចាំថានិយោជិតគ្រប់រូបមានសាវតារ និងបទពិសោធផ្ទាល់ខ្លួនរបស់ពួកគេ - សួរអំពីចំណូលចិត្តរបស់ពួកគេ ជាជាងធ្វើការសន្មតដោយផ្អែកលើក្រុមប្រជាសាស្ត្រដែលពួកគេស្ថិតក្នុង**
- **មានបំណងរៀបចំ និងអនុវត្តដំណើរការ គោលនយោបាយ ការអនុវត្ត លទ្ធផល និងសម្ភារៈទំនាក់ទំនងទាំងអស់ ដើម្បីឱ្យមានលទ្ធភាពចូលប្រើដោយស្មើភាពគ្នា និងពាក់ព័ន្ធចំពោះនិយោជិតទាំងអស់ មិនថាមានសាវតារ ឬលក្ខណៈផ្ទាល់ខ្លួនរបស់ពួកគេយ៉ាងណានោះទេ**

“កន្លែងធ្វើការរបស់យើងគឺជាកន្លែងមួយដែលនិយោជិតត្រូវបានប្រព្រឹត្តចំពោះគ្នាដោយសេចក្តីថ្លៃថ្នូរ សមធម៌ និងការគោរព”

ចុចទីនេះសម្រាប់ធនធានផ្ទៃក្នុង គោលការណ៍ Speaking Up

← ត្រឡប់ទៅទំព័រមាតិកា



ការអភិវឌ្ឍទេពកោសល្យ

យើងប្តេជ្ញាបង្កើតបរិយាកាសការងារដែលមានភាពសហការគ្នា និងផ្តល់អារម្មណ៍កក់ក្តៅដែលវិនិយោគក្នុងការគាំទ្រមិត្តរួមការងារក្នុងការបន្តអភិវឌ្ឍជំនាញ និងបទពិសោធន៍របស់ពួកគេ និងក្នុងការសម្រេចបាននូវសក្តានុពលអាជីពរបស់ពួកគេ។ យើងផ្តល់នូវការចូលប្រើកម្មវិធីជំនួយសម្រាប់និយោជិត ការងារដែលអាចបត់បែនបាន គោលការណ៍ និងបរិក្ខារដែលងាយស្រួលសម្រាប់គ្រួសារ ក៏ដូចជាសេវាថែទាំសុខភាពការងារ តាមតម្រូវការ។



- ត្រូវប្រាកដថាអ្នកចំណាយពេលសម្រាប់ការអភិវឌ្ឍផ្ទាល់ខ្លួន។ ចែករំលែកចំណេះដឹង និងបទពិសោធន៍ជាមួយអ្នកដទៃ ហើយរៀនពីពួកគេវិញ
- កុំផ្តោតលើលទ្ធផលពាណិជ្ជកម្មរយៈពេលខ្លីដោយត្រូវលះបង់ភាពសុចរិត ឬកំណើនប្រកបដោយនិរន្តរភាព
- កុំអនុញ្ញាតឱ្យមានផ្នត់គំនិតគ្រប់គ្រងប៉ះពាល់ដល់វិធីដែលអ្នកភ្ជាប់ទំនាក់ទំនង និងសហការជាមួយមិត្តរួមការងារ
- កុំលាក់បាំងកំហុស ឬចំណុចខ្វះខាត ឬបង្វែរកំហុសនៅពេលមានបញ្ហា

ចុចទីនេះសម្រាប់ធនធានផ្នែកក្នុង

“ការប្រើប្រាស់ការអនុវត្តកាតព្វកិច្ច និងសក្តានុពលរបស់មិត្តរួមការងារគ្រប់រូបនឹងគាំទ្រយើងក្នុងការសម្រេចបាននូវគោលដៅយុទ្ធសាស្ត្ររបស់យើង”

← ត្រឡប់ទៅទំព័រមាតិកា

ផ្តល់កន្លែងធ្វើការប្រកបដោយសុវត្ថិភាព សុខភាព និងការគាំទ្រ

សុខភាព សុវត្ថិភាព និងសុខុមាលភាពរបស់និយោជិតរបស់យើងគឺមានសារៈសំខាន់បំផុតសម្រាប់យើង។ យើងប្តេជ្ញាបង្កើតវប្បធម៌នៃការថែទាំ ដែលសុខុមាលភាព និងសុវត្ថិភាពជាអាទិភាពដាច់ខាត និងដើម្បីសម្រេចបាននូវស្តង់ដារសុខភាព សុវត្ថិភាព និងស្តង់ដារការងារលំដាប់ពិភពលោក នៅទូទាំងប្រតិបត្តិការជាសកលរបស់យើង។



- **កំណត់អត្តសញ្ញាណគ្រោះថ្នាក់ និងវាយតម្លៃហានិភ័យ ដើម្បីលុបបំបាត់ ឬគ្រប់គ្រងការគំរាមកំហែងសុវត្ថិភាពដែលអាចកើតមាន**
- **អនុវត្តតាមច្បាប់សម្រាប់ការប្រើប្រាស់ឧបករណ៍ យានជំនិះ គ្រឿងចក្រ និងឧបករណ៍ការពារផ្ទាល់ខ្លួន**
- **ទទួលខុសត្រូវក្នុងការគ្រប់គ្រងសុខភាព និងសុខុមាលភាពផ្ទាល់ខ្លួនរបស់អ្នក ដោយប្រកាន់យកអាកប្បកិរិយាដែលមានសុខភាពល្អ និងជូនដំណឹងដល់ អ្នកដឹកនាំក្រុម របស់អ្នក ប្រសិនបើអ្នកជឿថាការងារ ឬបរិយាកាសការងាររបស់អ្នក បង្កហានិភ័យដល់សុខភាពរបស់អ្នក ឬប្រសិនបើអ្នកមានតម្រូវការសម្រាប់ជំនួយបន្ថែម (ឧ. ការកែតម្រូវសម្រាប់ពិការភាព ឬការត្រឡប់ទៅធ្វើការវិញ)**
- **បន្តស្វែងរកការកែលម្អសុខភាព សុវត្ថិភាព និងការអនុវត្តសុខុមាលភាពរបស់យើង និងលើកទឹកចិត្តមិត្តរួមការងារឱ្យធ្វើដូចគ្នា**

“សុខភាព សុវត្ថិភាព និងសុខុមាលភាពរបស់និយោជិតរបស់យើងគឺមានសារៈសំខាន់បំផុតសម្រាប់យើង”

ចុចទីនេះសម្រាប់ធនធានផ្ទៃក្នុង គោលការណ៍សិទ្ធិមនុស្ស

← ត្រឡប់ទៅទំព័រមាតិកា

ការគោរពសិទ្ធិមនុស្ស

យើងផ្តល់តម្លៃលើសុវត្ថិភាព សេចក្តីថ្លៃថ្នូរ និងសុខុមាលភាពរបស់និយោជិតរបស់យើង ដៃគូអាជីវកម្មខាងក្រៅរបស់យើង និងសហគមន៍ដែលយើងធ្វើអាជីវកម្មជាមួយ។

យើងគោរពសិទ្ធិមនុស្ស រួមទាំងសិទ្ធិសេរីភាពក្នុងការបង្កើតសមាគម និងការទទួលយកការចរចាជាសមូហភាព ការលុបបំបាត់ពលកម្មការងារដោយបង្ខំ ឬបង្ខាប់បញ្ចា និងពលកម្មកុមារ។ ការលុបបំបាត់ការរើសអើងទាក់ទងនឹងការងារ និងមុខរបរ ក៏ដូចជាសិទ្ធិទទួលបានបរិយាកាសការងារប្រកបដោយសុវត្ថិភាព និងសុខភាពល្អនៅក្នុងប្រតិបត្តិការរបស់យើងផ្ទាល់ និងអ្នកផ្គត់ផ្គង់ និងដៃគូអាជីវកម្មខាងក្រៅរបស់យើង។ យើងត្រូវបានដឹកនាំដោយសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស និងសេចក្តីប្រកាសរបស់អង្គការពលកម្មអន្តរជាតិស្តីពីគោលការណ៍ជាមូលដ្ឋាន និងសិទ្ធិនៅកន្លែងធ្វើការ។



- **គ្មានបុគ្គលណាម្នាក់គួរត្រូវបានជួលដែលក្មេងជាងអាយុអប្បបរមាការងារស្របច្បាប់ក្នុងមូលដ្ឋាននោះទេ**
- **ពលកម្មកុមារ ពលកម្មការងារដោយបង្ខំ ឬជួញដូរ និងទម្រង់នៃទាសភាពណាមួយត្រូវបានហាមឃាត់។ ត្រូវហ៊ាននិយាយ ប្រសិនបើអ្នកសង្ស័យ ឬសង្កេតឃើញការរំលោភសិទ្ធិមនុស្សណាមួយ**
- **យើងប្តេជ្ញាធ្វើការឆ្ពោះទៅរកភាពគ្មានពលកម្មកុមារនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់របស់យើង។ យើងតម្រូវឱ្យអ្នកផ្គត់ផ្គង់របស់យើងគោរពតាម ឬអនុវត្តឱ្យបានលើសពីស្តង់ដារការងារអន្តរជាតិ ហើយកំណត់វានៅក្នុង ក្រមប្រតិបត្តិរបស់អ្នកផ្គត់ផ្គង់របស់យើង**
- **យើងយល់ និងប្រកាន់ខ្ជាប់នូវ គោលការណ៍សិទ្ធិមនុស្សរបស់យើង**



> **យើងផ្តល់តម្លៃលើសុវត្ថិភាព សេចក្តីថ្លៃថ្នូរ និងសុខុមាលភាពរបស់និយោជិតរបស់យើង ដៃគូអាជីវកម្មខាងក្រៅរបស់យើង និងសហគមន៍ដែលយើងធ្វើអាជីវកម្មជាមួយ**

ចុចទីនេះសម្រាប់ធនធានផ្ទៃក្នុង គោលការណ៍សិទ្ធិមនុស្ស
សេចក្តីថ្លែងការណ៍ស្តីពីទាសភាពទំនើប ក្រមប្រតិបត្តិរបស់អ្នកផ្គត់ផ្គង់

← ត្រឡប់ទៅទំព័រមាតិកា

ទ្រព្យសម្បត្តិ និងកេរ្តិ៍ឈ្មោះក្រុមហ៊ុនរបស់យើង

ការប្រតិបត្តិការអាជីវកម្មរបស់យើងដោយយកចិត្តទុកដាក់ និងឧស្សាហ៍ព្យាយាមអាចឱ្យយើងការពារទ្រព្យសម្បត្តិ និងកេរ្តិ៍ឈ្មោះរបស់ Imperial Brands និងធានាបាននូវអនាគតប្រកបដោយនិរន្តរភាពសម្រាប់ក្រុមហ៊ុនរបស់យើង។

21 ការប្រយុទ្ធប្រឆាំងនឹងការជួញដូរខុសច្បាប់

22 ការការពារទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន

23 ការការពារសន្តិសុខប្រព័ន្ធព័ត៌មាន

24 ការការពារព័ត៌មានផ្ទាល់ខ្លួន

25 ការគ្រប់គ្រងព័ត៌មានសម្ងាត់

26 ការការពារកម្មសិទ្ធិបញ្ញា

27 ការទំនាក់ទំនងជាមួយអ្នកវិនិយោគ អ្នកវិភាគ និងប្រព័ន្ធផ្សព្វផ្សាយ

28 ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមប្រកបដោយការទទួលខុសត្រូវ

> “ការប្រតិបត្តិអាជីវកម្មរបស់យើង ដោយយកចិត្តទុកដាក់ និងឧស្សាហ៍ព្យាយាម អាចឱ្យយើងការពារទ្រព្យសម្បត្តិ និងកេរ្តិ៍ឈ្មោះរបស់ Imperial Brands បាន”

← ត្រឡប់ទៅទំព័រមាតិកា

ការប្រយុទ្ធប្រឆាំងនឹងការជួញដូរខុសច្បាប់

យើងប្រឆាំងនឹងការជួញដូរខុសច្បាប់គ្រប់ទម្រង់ និងសហការជាមួយអាជ្ញាធរដើម្បីទប់ស្កាត់ផលិតផលថ្នាំជក់ខុសច្បាប់មិនឱ្យមានផ្លូវចូលទៅក្នុងទីផ្សារស្របច្បាប់។ ដោយមានភស្តុតាងច្បាស់លាស់ថាការជួញដូរខុសច្បាប់បានផ្តល់មូលនិធិដល់ឧក្រិដ្ឋកម្ម និងអំពើភេរវកម្មដែលបានរៀបចំនៅជុំវិញពិភពលោក ការលុបបំបាត់វានៅតែបន្តជាអាទិភាពមួយក្នុងចំណោមអាទិភាពចម្បងរបស់យើង។



- ផ្គត់ផ្គង់ផលិតផលតែក្នុងបរិមាណសមស្របជាមួយនឹងការប្រើប្រាស់ក្នុងស្រុកនៅក្នុងទីផ្សារគោលដៅ និងលក្ខខណ្ឌតម្រូវដែលអាចអនុញ្ញាតបានរបស់អ្នកប្រើប្រាស់ធ្វើដំណើរ
- ធ្វើឱ្យអតិថិជនដឹងពីជំហររបស់ Imperial Brands ប្រឆាំងនឹងការជួញដូរខុសច្បាប់ និងការទទួលខុសត្រូវរបស់ពួកគេក្នុងការអនុវត្តតាមច្បាប់ និងស្តង់ដាររបស់យើង
- សហការជាមួយរដ្ឋាភិបាល ឬអាជ្ញាធរអនុវត្តច្បាប់ណាមួយក្នុងការស៊ើបអង្កេតលើការបង្វែរផលិតផល
- កុំដាក់ខ្លួនអ្នកទៅក្នុងស្ថានភាពដែលមានហានិភ័យ ឬគ្រោះថ្នាក់នៅពេលប្រមូល ឬរាយការណ៍អំពីការជួញដូរខុសច្បាប់នោះទេ

> យើងប្រឆាំងនឹងការជួញដូរខុសច្បាប់គ្រប់ទម្រង់ និងសហការជាមួយអាជ្ញាធរដើម្បីទប់ស្កាត់ផលិតផលថ្នាំជក់ខុសច្បាប់មិនឱ្យមានផ្លូវចូលទៅក្នុងទីផ្សារស្របច្បាប់

ចុចទីនេះសម្រាប់ធនធានផ្ទៃក្នុង

← ត្រឡប់ទៅទំព័រមាតិកា



ការការពារទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន

ការប្រើប្រាស់ទ្រព្យសកម្ម និងធនធានរបស់ក្រុមហ៊ុនមិនសមរម្យអាចជះឥទ្ធិពលផ្ទាល់ទៅលើផលចំណេញនៃអាជីវកម្មរបស់យើង។ ការប្រើប្រាស់កុំព្យូទ័រយួរដៃ និងទូរសព្ទ ឧបករណ៍ (ដូចជាយានជំនិះ) សម្ភារៈបរិក្ខារ ពត៌មាន កម្មសិទ្ធិបញ្ញា និងថវិការបស់ក្រុមហ៊ុនឱ្យបានត្រឹមត្រូវគឺជាកាតព្វកិច្ច និងអនុវត្តចំពោះសហសេវិក Imperial Brands ទាំងអស់។



- ប្រើប្រាស់ទ្រព្យសម្បត្តិ និងថវិការបស់ Imperial Brands ដើម្បីផលប្រយោជន៍ល្អបំផុតសម្រាប់ក្រុមហ៊ុន
- អនុវត្តតាមគោលការណ៍របស់ក្រុមហ៊ុនលើការប្រើប្រាស់ប្រព័ន្ធព័ត៌មានដូចជា អ៊ីមែល ឬ ទូរសព្ទ
- គោរពទ្រព្យសម្បត្តិ និងធនធានដែលជាកម្មសិទ្ធិរបស់ក្រុមហ៊ុន និងអង្គភាពផ្សេងទៀតដូចជាអតិថិជន និងដៃគូអាជីវកម្មខាងក្រៅ
- មិនត្រូវប្រើប្រាស់ធនធានក្រុមហ៊ុន ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនឡើយ

“ការប្រើប្រាស់ទ្រព្យសកម្ម និងធនធានរបស់ក្រុមហ៊ុនមិនសមរម្យអាចជះឥទ្ធិពលផ្ទាល់ទៅលើផលចំណេញនៃអាជីវកម្មរបស់យើង”

ចុចទីនេះសម្រាប់ធនធានផ្ទៃក្នុង

← ត្រឡប់ទៅទំព័រមាតិកា

ការការពារសន្តិសុខប្រព័ន្ធព័ត៌មាន

យើងរក្សាព័ត៌មានរបស់ក្រុមហ៊ុន ដំណើរការអាជីវកម្ម និងប្រព័ន្ធឱ្យមានសុវត្ថិភាពពីការចូលប្រើប្រាស់ខុស ការលួច ការបំផ្លាញ ឬការចូលប្រើប្រាស់ដោយគ្មានការអនុញ្ញាត ការផ្លាស់ប្តូរ និងការបង្ហាញ។ យើងរក្សាការប្រុងប្រយ័ត្នប្រឆាំងនឹងការគំរាមកំហែងតាមអ៊ីនធឺណិតគ្រប់ពេលវេលា។



- **រាយការណ៍រាល់ឧប្បត្តិហេតុសន្តិសុខដែលសង្ស័យ ឬការរំលោភបំពានទិន្នន័យភ្លាមៗ ទៅកាន់ផ្នែកសេវាកម្មរបស់អ្នក**
- **រាយការណ៍អ៊ីមែលបន្លំដែលសង្ស័យទាំងអស់ដោយប្រើប៊ូតុង "Report Phishing" ក្នុង Outlook**
- **ប្រើឃ្លាវែងយ៉ាងហោចណាស់ 16 តួ ហើយប្រើការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវច្រើនកត្តា (MFA) ដែលមាន**
- **យកចិត្តទុកដាក់បន្ថែមនៅពេលធ្វើការនៅខាងក្រៅការិយាល័យ**

យើងបន្តការប្រុងប្រយ័ត្នប្រឆាំងនឹងការគំរាមកំហែងតាមអ៊ីនធឺណិតគ្រប់ពេលវេលា

ចុចទីនេះសម្រាប់ធនធានផ្ទៃក្នុង

← ត្រឡប់ទៅទំព័រមាតិកា

ការការពារព័ត៌មានផ្ទាល់ខ្លួន

យើងគោរពភាពឯកជនរបស់សហសេវិក អ្នកម៉ៅការ អ្នកប្រើប្រាស់ អតិថិជន និងដៃគូអាជីវកម្មខាងក្រៅរបស់យើង។ យើងប្ដេជ្ញាគ្រប់គ្រងព័ត៌មានផ្ទាល់ខ្លួនដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិស្ដីពីឯកជនភាពទិន្នន័យដែលអាចអនុវត្តបាន។



- ប្រមូល ឬប្រើព័ត៌មានផ្ទាល់ខ្លួនដែលអ្នកត្រូវការសម្រាប់គោលបំណងស្របច្បាប់ប៉ុណ្ណោះ
- ចែករំលែកព័ត៌មានផ្ទាល់ខ្លួនលុះត្រាតែមានការអនុញ្ញាតិឱ្យធ្វើដូច្នេះ និងមានការគ្រប់គ្រងសមស្រប ជាពិសេសប្រសិនបើការចែករំលែកនៅក្រៅប្រទេសដែលវាត្រូវបានប្រមូល
- ការពារព័ត៌មានផ្ទាល់ខ្លួនណាមួយដែលអ្នកគ្រប់គ្រង ហើយរក្សាទុកវាដល់រយៈពេលចាំបាច់សម្រាប់គោលបំណងដែលវាត្រូវបានប្រមូល ឬបំពេញតាមលក្ខខណ្ឌតម្រូវច្បាប់អប្បបរមាប៉ុណ្ណោះ
- ពន្យល់ប្រាប់បុគ្គលម្នាក់ៗអំពីមូលហេតុដែលយើងត្រូវការព័ត៌មានផ្ទាល់ខ្លួន របៀបដែលវានឹងត្រូវបានប្រើ និងសិទ្ធិរបស់ពួកគេ



> យើងគោរពភាពឯកជនរបស់សហសេវិក អ្នកម៉ៅការ អ្នកប្រើប្រាស់ អតិថិជន និងដៃគូអាជីវកម្មខាងក្រៅរបស់យើង

សូមចុចទីនេះសម្រាប់ធនធានផ្ទៃក្នុង ការជូនដំណឹងអំពីឯកជនភាព Imperial Brands

← ត្រឡប់ទៅទំព័រមាតិកា

ការគ្រប់គ្រងព័ត៌មានសម្ងាត់

យើងការពារព័ត៌មានអ្នកប្រើប្រាស់ អតិថិជន ក្រុមហ៊ុន និងព័ត៌មាននិយោជិត។ យើងយកចិត្តទុកដាក់នៅពេលគ្រប់គ្រងព័ត៌មានសម្ងាត់ ហើយចែករំលែកវាជាមួយអ្នកដែលត្រូវការមើលវាប៉ុណ្ណោះ។ យើងគោរពព័ត៌មានសម្ងាត់របស់អ្នកដទៃ រួមទាំងដៃគូប្រកួតប្រជែងរបស់យើង។



- **ចែករំលែកព័ត៌មានសម្ងាត់តែជាមួយតែអ្នកដែលត្រូវការដឹង ឬមានសិទ្ធិដឹង ដោយធានាថាពួកគេយល់ពីការរឹតបន្តឹងណាមួយដែលអនុវត្ត**
- **ទទួលបានការអនុញ្ញាតចាំបាច់ រួមទាំងការអនុញ្ញាតពិសេស ការរក្សាការសម្ងាត់ ការមិនបង្ហាញ ឬកិច្ចព្រមព្រៀងដំណើរការទិន្នន័យ នៅពេលចែករំលែកព័ត៌មាននៅខាងក្រៅ Imperial Brands**
- **ប្រើស្លាកសញ្ញាភាពរសើបសមស្រប និងការអ៊ិនគ្រីបដើម្បីការពារព័ត៌មានសម្ងាត់។ ប្រើស្រទាប់ការពារអេក្រង់មានឯកជនភាព ហើយមានការប្រុងប្រយ័ត្នក្នុងការពិភាក្សាអំពីបញ្ហាសម្ងាត់ នៅពេលធ្វើការនៅកន្លែងសាធារណៈ**
- **មិនត្រូវប្រើសេវាកម្មផ្ញើសារបន្ទាន់ផ្ទាល់ខ្លួន ឬមិនមែនរបស់ក្រុមហ៊ុន សេវាកម្មអ៊ីមែល ការចែករំលែកឯកសារ និងសេវាកម្មរក្សាទុកសម្រាប់អាជីវកម្មរបស់ក្រុមហ៊ុនឡើយ**

“យើងគោរពព័ត៌មានសម្ងាត់របស់អ្នកដទៃ រួមទាំងដៃគូប្រកួតប្រជែងរបស់យើង”

ចុចទីនេះសម្រាប់ធនធានផ្ទៃក្នុង

← ត្រឡប់ទៅទំព័រមាតិកា



ការការពារកម្មសិទ្ធិបញ្ញា

សិទ្ធិនៃកម្មសិទ្ធិបញ្ញារបស់យើង ដូចជាពាណិជ្ជសញ្ញា សិទ្ធិរចនា ប៉ាតង់ និងសិទ្ធិថតចម្លង គឺជាទ្រព្យសម្បត្តិដ៏មានតម្លៃដែលការពារម៉ាកសញ្ញា និងការច្នៃប្រឌិតរបស់យើង ហើយផ្តល់ឱ្យយើងនូវអត្ថប្រយោជន៍ប្រកួតប្រជែង។ ប្រសិនបើទ្រព្យសម្បត្តិកម្មសិទ្ធិបញ្ញារបស់យើងត្រូវបានប្រើប្រាស់ខុស ផលប្រយោជន៍របស់យើង និងអ្នកប្រើប្រាស់របស់យើងអាចត្រូវរងហានិភ័យ។



- ការពារកម្មសិទ្ធិបញ្ញារបស់យើង និងរាយការណ៍ពីផលិតផល 'ចម្លង' ណាមួយ ផលិតផលក្លែងក្លាយ ឬវត្ថុផ្សេងទៀតដែលអាចរំលោភលើកម្មសិទ្ធិបញ្ញារបស់ Imperial Brands
- នៅពេលចូលរួមជាមួយដៃគូរបស់យើង ត្រូវប្រាកដថាត្រូវគិតគូរអំពីកម្មសិទ្ធិបញ្ញាជានិច្ច និងធានានូវកិច្ចសន្យាដែលសមស្រប ដូចជាកិច្ចព្រមព្រៀងមិនបង្ហាញព័ត៌មាន ឬកិច្ចព្រមព្រៀងអភិវឌ្ឍន៍ជាដើម
- គោរពកម្មសិទ្ធិបញ្ញារបស់អ្នកដទៃ រួមទាំងអតិថិជន ដៃគូប្រកួតប្រជែង និងដៃគូអាជីវកម្មខាងក្រៅ
- មិនត្រូវប្រើឈ្មោះ ពាណិជ្ជសញ្ញា ឬធាតុរចនាផ្សេងទៀត ដែលអ្នកប្រើប្រាស់អាចភ្ជាប់ជាមួយអ្នកដទៃ នៅពេលលក់ ធ្វើទីផ្សារ ឬផ្សព្វផ្សាយផលិតផលរបស់យើងឡើយ

"យើងសហការរវាងផ្នែកនៃមុខងារនានាដើម្បីធានាថាយើងការពារកម្មសិទ្ធិបញ្ញារបស់យើង ហើយយើងគោរពសិទ្ធិកម្មសិទ្ធិបញ្ញារបស់អ្នកដទៃ"



ចុចទីនេះសម្រាប់ធនធានផ្ទៃក្នុង

← ត្រឡប់ទៅទំព័រមាតិកា

ការទំនាក់ទំនងជាមួយអ្នកវិនិយោគ អ្នកវិភាគ និងប្រព័ន្ធផ្សព្វផ្សាយ

យើងបង្ហាញសារច្បាស់លាស់ និងជាប់លាប់ក្នុងការទំនាក់ទំនងជាមួយអ្នកវិនិយោគ អ្នកវិភាគ និងប្រព័ន្ធផ្សព្វផ្សាយ។ អ្វីគ្រប់យ៉ាងដែលយើងធ្វើ និងនិយាយ និងអ្វីគ្រប់យ៉ាងដែលភាគីពាក់ព័ន្ធខាងក្រៅនិយាយអំពីយើង មានឥទ្ធិពលដល់កេរ្តិ៍ឈ្មោះរបស់យើង។ ភាគទុនិក អ្នកវិភាគ អតិថិជន និងអ្នកផ្សេងទៀតជាច្រើនពឹងផ្អែកលើយើងក្នុងការផ្តល់ព័ត៌មានត្រឹមត្រូវ និងគួរឱ្យទុកចិត្តអំពីប្រតិបត្តិការ ការអនុវត្ត និងទស្សនវិស័យហិរញ្ញវត្ថុរបស់យើង។





- ត្រូវប្រាកដថាមានតែសហការីដែលបានទទួលការបណ្តុះបណ្តាល និងមានសិទ្ធិប៉ុណ្ណោះ អាចនិយាយទៅកាន់អ្នកវិនិយោគ អ្នកវិភាគ និងប្រព័ន្ធផ្សព្វផ្សាយ
- បញ្ជូនការសាកសួររបស់ប្រព័ន្ធផ្សព្វផ្សាយទាំងឡាយទៅកាន់ក្រុមទំនាក់ទំនងក្នុងតំបន់របស់អ្នក ឬផ្នែកទំនាក់ទំនងរបស់ Group
- បញ្ជូនសំណួររបស់អ្នកវិនិយោគ ឬអ្នកវិភាគណាមួយទៅក្រុមទំនាក់ទំនងវិនិយោគិននៅក្នុងការិយាល័យកណ្តាល
- មិនត្រូវធ្វើជាតំណាងឱ្យអាជីវកម្មនៅខាងក្រៅឡើយ លុះត្រាតែមានការបណ្តុះបណ្តាល និងអនុញ្ញាតឱ្យធ្វើដូច្នេះ

> យើងបង្ហាញសារច្បាស់លាស់ និងជាប់លាប់ក្នុងការទំនាក់ទំនងជាមួយអ្នកវិនិយោគ អ្នកវិភាគ និងប្រព័ន្ធផ្សព្វផ្សាយ



ចុចទីនេះសម្រាប់ធនធានផ្ទៃក្នុង

← ត្រឡប់ទៅទំព័រមាតិកា

ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមប្រកបដោយការទទួលខុសត្រូវ

យើងប្តេជ្ញាចំពោះការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមប្រកបដោយការទទួលខុសត្រូវ និងតម្លាភាព ដើម្បីជួយយើងចែករំលែកព័ត៌មានអំពីក្រុមហ៊ុនរបស់យើង។ ការយល់ដឹង និងការអនុលោមតាមការណែនាំដែលផ្តល់ដោយអាជីវកម្មលើការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់យើង គឺជាទំនួលខុសត្រូវរបស់សហសេវិក Imperial Brands គ្រប់រូប។



- **ត្រូវកំណត់អត្តសញ្ញាណខ្លួនអ្នកជានិយោជិត ប្រសិនបើគាំទ្រសម្រាប់ក្រុមហ៊ុន ឬសកម្មភាពរបស់យើង**
- **ត្រូវដឹងពីការរឹតបន្តឹងផ្លូវច្បាប់ដែលអាចអនុវត្តចំពោះការទំនាក់ទំនងអំពីអាជីវកម្មរបស់យើងនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម**
- **ត្រូវប្រុងប្រយ័ត្នអំពីការយល់ឃើញរបស់អ្នកដទៃទៀតទៅលើការបង្ហោះរបស់អ្នកនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម**
- **មិនត្រូវបង្ហាញព័ត៌មានសម្ងាត់ ឯកជន ឬកម្មសិទ្ធិអំពីក្រុមហ៊ុន ឬអតិថិជន អ្នកផ្គត់ផ្គង់ ឬសហការីរបស់ខ្លួននៅលើប្រព័ន្ធផ្សព្វផ្សាយសង្គមឡើយ**



> **ការអនុលោមតាមការណែនាំដែលផ្តល់ដោយអាជីវកម្មលើការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់យើងគឺជាការទទួលខុសត្រូវរបស់សហសេវិក Imperial Brands គ្រប់រូប**

ចុចទីនេះសម្រាប់ធនធានផ្ទៃក្នុង

← ត្រឡប់ទៅទំព័រមាតិកា

សុចរិតភាពអាជីវកម្មរបស់យើង

ការធ្វើសកម្មភាពប្រកបដោយទំនួលខុសត្រូវ និងសុចរិតភាព បានអនុញ្ញាតឱ្យក្រុមហ៊ុន Imperial Brands បង្កើត និងរក្សានិរន្តរភាពអាជីវកម្មដែលជោគជ័យ។ យើងជឿជាក់លើការជឿទុកចិត្ត ភាពយុត្តិធម៌ និងភាពស្មោះត្រង់ ហើយអ្វីគ្រប់យ៉ាងដែលយើងធ្វើឆ្លុះបញ្ចាំងពីកត្តានេះ។ យើងមិនមានការអត់ឱនចំពោះទម្រង់នៃការសូកប៉ាន់ អំពើពុករលួយ ឬគណនេយ្យក្លែងបន្លំណាមួយឡើយ។

30 ការទប់ស្កាត់ការស៊ីសំណូក និងអំពើពុករលួយ

31 ការផ្តល់ និងទទួលអំណោយ និងការកម្សាន្ត

32 ការគ្រប់គ្រងទំនាស់ផលប្រយោជន៍

33 ការប្រកួតប្រជែងដោយយុត្តិធម៌

34 ការប្រមូលព័ត៌មានប្រកួតប្រជែង

35 ការហាមឃាត់ការជួញដូរផ្ទៃក្នុង

36 របាយការណ៍ហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុសុក្រិត

37 ការអនុលោមតាមលក្ខខណ្ឌតម្រូវនៃគយ និងពន្ធ

38 ការអនុលោមតាមការដាក់ទណ្ឌកម្ម និងការរឹតបន្តឹងពាណិជ្ជកម្ម

39 ការលាងលុយកខ្វក់

40 ទំនាក់ទំនងអ្នកផ្គត់ផ្គង់ដែលជឿទុកចិត្ត

41 ការចូលរួមជាមួយរដ្ឋាភិបាល និងស្ថាប័ននយោបាយ

> **“យើងទទួលខុសត្រូវដោយភាពជឿជាក់ និងមិនធ្វើឱ្យខូចដល់សុចរិតភាពសម្រាប់ផលប្រយោជន៍ពាណិជ្ជកម្មឡើយ”**

← ត្រឡប់ទៅទំព័រមាតិកា

ការទប់ស្កាត់ការស៊ីសំណូក និង អំពើពុករលួយ

យើងមានមោទនភាពចំពោះកេរ្តិ៍ឈ្មោះរបស់យើងក្នុងការធ្វើអាជីវកម្មតាមរបៀបត្រឹមត្រូវ។ ការអនុលោមតាមច្បាប់ស្តីពីការស៊ីសំណូក និងអំពើពុករលួយគឺជាកាតព្វកិច្ច គ្រប់ទីកន្លែងដែលយើងធ្វើអាជីវកម្ម ហើយច្បាប់ទាំងនេះមួយចំនួនអាចត្រូវបានអនុវត្តឆ្លងព្រំដែន។ ការបំពានច្បាប់ស៊ីសំណូក និងអំពើពុករលួយ គឺជាបទល្មើសព្រហ្មទណ្ឌដ៏ធ្ងន់ធ្ងរមួយសម្រាប់ក្រុមហ៊ុន និងបុគ្គលដែលពាក់ព័ន្ធ ហើយអាចបណ្តាលឱ្យមានការផាកពិន័យចំនួនច្រើន និងអាចជាប់ពន្ធនាគារទៀតផង។



- **មិនត្រូវផ្តល់ ទូទាត់ ឬទទួលសំណូក ដោយមិនគិតថាវាជាច្បាប់ ឬវប្បធម៌ក្នុងតំបន់នោះទេ**
- **មិនត្រូវសុំ ឬអនុញ្ញាតឱ្យអ្នកដ៏ទៃធ្វើការទូទាត់ពុករលួយក្នុងនាមយើងឡើយ**
- **មិនត្រូវផ្តល់ ឬឱ្យអ្វីមួយដែលមានតម្លៃជាសាច់ប្រាក់ដល់នរណាម្នាក់ ក្នុងគោលបំណងធានារក្សា ឬសម្របសម្រួលអាជីវកម្ម (ដូចជាការទូទាត់ដើម្បីកាត់បន្ថយពន្ធ ឬពន្ធគយ)**
- **ធ្វើការតែជាមួយអ្នកប្រឹក្សា និងអ្នកប្រឹក្សាយោបល់ដែលបានបញ្ជាក់ពីភាពស្អាតស្អំដោយការត្រួតពិនិត្យ មានការយល់ព្រមជាផ្លូវការ និងមានកាតព្វកិច្ចតាមកិច្ចសន្យាដើម្បីបំពេញតាមស្តង់ដាររបស់យើងប៉ុណ្ណោះ**

“យើងមានមោទនភាពចំពោះកេរ្តិ៍ឈ្មោះរបស់យើងក្នុងការធ្វើអាជីវកម្មតាមរបៀបត្រឹមត្រូវ”

ចុចទីនេះសម្រាប់ធនធានផ្ទៃក្នុង

ការផ្ដល់ និងទទួលអំណោយ និការកម្សាន្ត

យើងមានបំណងបង្កើតទំនាក់ទំនងដ៏រឹងមាំ និងគួរឱ្យទុកចិត្តជាមួយដៃគូអាជីវកម្មខាងក្រៅ និងផ្លាស់ប្ដូរអំណោយ និងការកម្សាន្តដើម្បីបង្ហាញការគួរសម និងបង្កើតសុច្ឆន្ទៈ។ ទោះជាយ៉ាងណាក៏ដោយ ការផ្លាស់ប្ដូរអំណោយ ការធ្វើបដិសណ្ឋារកិច្ច និងការកម្សាន្តមិនត្រឹមត្រូវអាចត្រូវបានគេចាត់ទុកថាជាសំណូក និងធ្វើឱ្យខូចដល់ភាពស្មោះត្រង់របស់យើង។



- **ផ្ដល់ និងទទួលតែអំណោយ និងការកម្សាន្តដែលសមហេតុផល និងសមាមាត្រ និងមានគោលបំណងអាជីវកម្មសមហេតុផលប៉ុណ្ណោះ**
- **មិនត្រូវផ្ដល់ ឬទទួលយកអំណោយ ឬការកម្សាន្តដែលមានបំណង ឬដែលអាចត្រូវបានចាត់ទុកថាជាការប៉ុនប៉ងដើម្បីជះឥទ្ធិពលមិនត្រឹមត្រូវដល់ការសម្រេចចិត្តអាជីវកម្ម ឬទទួលបានអត្ថប្រយោជន៍នោះទេ**
- **មិនត្រូវផ្ដល់អំណោយ ឬការកម្សាន្តដល់មន្ត្រីសាធារណៈ ឬមន្ត្រីរដ្ឋាភិបាលនោះទេ លើកលែងតែត្រឹមត្រូវតាមច្បាប់ និងមានការអនុញ្ញាតជាមុន**
- **មិនត្រូវផ្ដល់ ឬទទួលយកសាច់ប្រាក់ ឬវត្ថុមានតម្លៃជាសាច់ប្រាក់ជាអំណោយនោះទេ**

មិនអាចទទួលយកបានដាច់ខាត៖

- សាច់ប្រាក់ ឬមានតម្លៃជាសាច់ប្រាក់
- អ្វីក៏ដោយដែលខុសច្បាប់ដែលផ្ទុយនឹងគោលការណ៍ក្រុមហ៊ុន ឬដែលអាចប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់ក្រុមហ៊ុនរបស់យើង
- អំណោយដោយគ្មានគោលបំណងអាជីវកម្មសមហេតុផល

ជាធម្មតាអាចទទួលយកបាន៖

- អាហារជាមួយដៃគូអាជីវកម្មខាងក្រៅ អតិថិជន ឬអ្នកផ្គត់ផ្គង់
- ការអញ្ជើញឱ្យចូលរួមព្រឹត្តិការណ៍កីឡា ល្ខោន ឬព្រឹត្តិការណ៍វប្បធម៌ ប្រសិនបើមានគោលបំណងអាជីវកម្មសមហេតុផល
- វត្ថុផ្សព្វផ្សាយដែលមានតម្លៃតិចតួច

សូមចងចាំថាអំណោយ និងការកម្សាន្តទាំងអស់ដែលមានតម្លៃ **លើសពី 100 GBP** ឬដែនកំណត់ទីផ្សារក្នុងស្រុកត្រូវតែចុះបញ្ជី។

“យើងមិនផ្ដល់ ឬទទួលយកអំណោយ ឬការកម្សាន្តនោះទេ ប្រសិនបើការធ្វើបែបនេះអាចបង្កឱ្យមាន ឬនាំឱ្យគេយល់ឃើញថាជាការសូកប៉ាន់”

ចុចទីនេះសម្រាប់ធនធានផ្ទៃក្នុង

← ត្រឡប់ទៅទំព័រមាតិកា



ការគ្រប់គ្រងទំនាស់ផលប្រយោជន៍

ទំនាស់ផលប្រយោជន៍អាចជារឿងផ្ទាល់ខ្លួន ឬទាក់ទងនឹងអាជីវកម្ម ហើយអាចប៉ះពាល់ដល់សមត្ថភាពរបស់យើងក្នុងការសម្រេចចិត្តដោយយុត្តិធម៌ និងជាផលប្រយោជន៍របស់ Imperial Brands ។ យើងប្តេជ្ញាចិត្តក្នុងការគ្រប់គ្រងទំនាស់យ៉ាងសកម្ម ដើម្បីធានាថាវាមិនធ្វើឱ្យខូចដល់សុចរិតភាពរបស់យើង។



- **ធ្វើសកម្មភាពដោយសុចរិតភាព និងតម្លាភាព និងជៀសវាងស្ថានភាពដែលទំនាក់ទំនងផ្ទាល់ខ្លួន ឬផលប្រយោជន៍ហិរញ្ញវត្ថុមានទំនាស់ជាមួយផលប្រយោជន៍របស់ Imperial Brands**
- **ប្រកាសអំពីទំនាស់ផលប្រយោជន៍ជាក់ស្តែង សក្តានុពល ឬដោយយល់ឃើញភ្លាមៗតាមដែលបានដឹង**
- **សហការ និងគ្រប់គ្រងទំនាស់ប្រកបដោយតម្លាភាព និងគិតគូរអំពីផលប្រយោជន៍របស់ Imperial Brands**
- **មិនត្រូវប្រើតួនាទីរបស់អ្នកមិនត្រឹមត្រូវដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ឬផលប្រយោជន៍របស់នរណាម្នាក់ដែលអ្នកមានទំនាក់ទំនងផ្ទាល់ខ្លួននោះទេ**

> **យើងប្តេជ្ញាចិត្តក្នុងការគ្រប់គ្រងទំនាស់យ៉ាងសកម្ម ដើម្បីធានាថាវាមិនធ្វើឱ្យខូចដល់សុចរិតភាពរបស់យើង**



ចុចទីនេះសម្រាប់ធនធានផ្ទៃក្នុង

← ត្រឡប់ទៅទំព័រមាតិកា

ប្រកួតប្រជែងដោយយុត្តិធម៌

Imperial Brands ប្តេជ្ញាចិត្តក្នុងការប្រកួតប្រជែងដោយយុត្តិធម៌ ស្របច្បាប់ និងស្មោះត្រង់។ យើងអនុវត្តតាមច្បាប់ប្រឆាំងការរំលោភលើសេចក្តីទុកចិត្ត និងការប្រកួតប្រជែងទាំងអស់ ដែលអនុវត្តចំពោះអាជីវកម្មរបស់យើង។



- **ត្រូវប្រាកដថាអ្នកយល់ និងអនុលោមតាមច្បាប់ប្រកួតប្រជែងដែលអនុវត្តចំពោះទីផ្សាររបស់អ្នក គោលនយោបាយរបស់យើង និងការបណ្តុះបណ្តាល ឬសម្ភារៈណែនាំដែលពាក់ព័ន្ធផ្សេងទៀត**
- **មិនត្រូវចុះកិច្ចព្រមព្រៀងប្រឆាំងការប្រកួតប្រជែង (ឧ. ការកំណត់តម្លៃ ការដាក់ដេញថ្លៃ ការចែករំលែកទីផ្សារ)។ ត្រូវដំណើរការ និងប្រកួតប្រជែងដោយឯករាជ្យពីដៃគូប្រកួតប្រជែងរបស់យើងជានិច្ច**
- **មិនត្រូវពិភាក្សាអំពីប្រធានបទរសើបនៃពាណិជ្ជកម្មជាមួយដៃគូប្រកួតប្រជែង ដូចជាតម្លៃ លក្ខខណ្ឌពាណិជ្ជកម្ម ឬការបើកដំណើរការផលិតផលថ្មីឡើយ**
- **ប្រសិនបើអ្នកទទួលបានព័ត៌មានរសើបពាណិជ្ជកម្ម សូមឆ្លើយតបដោយបញ្ជាក់ថាអ្នកមិនបានស្នើសុំវា មិនទទួលយកវា ហើយអ្នកផ្ញើមិនគួរផ្ញើអ្វីបន្ថែមទៀតទេ។ ប្រសិនបើអ្នកបន្តទទួលបានព័ត៌មានបែបនេះក្នុងអំឡុងពេលប្រជុំ សូមចាកចេញពីកិច្ចប្រជុំ ហើយរាយការណ៍ពីឧប្បត្តិហេតុនេះទៅកាន់អ្នកប្រឹក្សាផ្នែកច្បាប់ក្នុងតំបន់របស់អ្នក ឬផ្នែកច្បាប់របស់ Group ជាបន្ទាន់។**

តើអ្វីជាព័ត៌មានរសើបពាណិជ្ជកម្ម (CSI)?

ព័ត៌មានរសើបពាណិជ្ជកម្ម (CSI) គឺជាព័ត៌មានដែលមិនមែនសាធារណៈអំពីគោលនយោបាយពាណិជ្ជកម្មរបស់អាជីវកម្មដែលអាចមានឥទ្ធិពលលើអាកប្បកិរិយារបស់គូប្រកួតប្រជែង។ វារួមបញ្ចូល (ប៉ុន្តែមិនកំណត់ចំពោះតែ) ព័ត៌មានដែលទាក់ទងនឹងយុទ្ធសាស្ត្រពាណិជ្ជកម្មរបស់អាជីវកម្ម ការកំណត់តម្លៃនាពេលអនាគត អាថ៌កំបាំងពាណិជ្ជកម្ម កម្មសិទ្ធិបញ្ញា និងកំណត់ត្រាអតិថិជន និងអ្នកផ្គត់ផ្គង់។ ប្រសិនបើអ្នកមានការសង្ស័យអំពីអ្វីដែលជា CSI សូមនិយាយទៅកាន់អ្នកប្រឹក្សាច្បាប់ក្នុងតំបន់របស់អ្នកឬផ្នែកច្បាប់របស់ Group ។

> **“យើងអនុវត្តតាមច្បាប់ប្រឆាំងការរំលោភលើសេចក្តីទុកចិត្ត និងការប្រកួតប្រជែងទាំងអស់ ដែលអនុវត្តចំពោះអាជីវកម្មរបស់យើង”**

ចុចទីនេះសម្រាប់ធនធានផ្ទៃក្នុង



← ត្រឡប់ទៅទំព័រមាតិកា

ការប្រមូលព័ត៌មានប្រកួតប្រជែង

យើងតាមដានបរិយាកាសប្រកួតប្រជែងរបស់យើង និងវិភាគនិន្នាការដើម្បីអភិវឌ្ឍអាជីវកម្មរបស់យើង ដូច្នេះយើងអាចបំពេញតម្រូវការអតិថិជនរបស់យើងបាន។



- **អនុវត្តតាមច្បាប់ប្រកួតប្រជែងដែលពាក់ព័ន្ធទាំងអស់ នៅពេលប្រមូល ទទួល ឬផ្លាស់ប្តូរព័ត៌មាន**
- **មិនត្រូវផ្លាស់ប្តូរ ជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់ ជាផ្លូវការ ឬក្រៅផ្លូវការ នូវព័ត៌មានរសើបពាណិជ្ជកម្ម ឬទិន្នន័យជាមួយដៃគូប្រកួតប្រជែង (រួមទាំងតាមរយៈអន្តរការី ឬភាគីទីបី)**
- **ទទួលយកការយល់ព្រមពីទីប្រឹក្សាច្បាប់ក្នុងតំបន់ អ្នកប្រឹក្សាផ្នែកច្បាប់ខាងក្រៅ ឬអ្នកច្បាប់របស់ Group មុនពេលប្រមូល ឬទទួលយកប្រភពទិន្នន័យថ្មីអំពីនិន្នាការទីផ្សារ ឬសកម្មភាពប្រកួតប្រជែង (រួមទាំងតាមរយៈភាគីទីបី)**
- **សូមប្រាកដថារបាយការណ៍ឧស្សាហកម្មណាមួយឬការស្ទង់មតិគោលដែលយើងផ្តល់ទិន្នន័យ (ដូចជាទិន្នន័យតម្លៃ/បរិមាណ) ត្រូវបានប្រមូលផ្តុំគ្នាយ៉ាងសមរម្យជាប្រវត្តិ និងមិនមែនជាការព្យាករទៅថ្ងៃមុខ**

តើអ្វីជាប្រភពព័ត៌មានដែលអាចទទួលយកបាននៃការប្រកួតប្រជែង?

- ប្រព័ន្ធផ្សព្វផ្សាយ
- ប្រភពដែលអាចចូលប្រើជាសាធារណៈនៅលើអ៊ីនធឺណិត រួមទាំងគេហទំព័ររបស់ក្រុមហ៊ុនផងដែរ
- ការស្ទង់មតិឧស្សាហកម្មល្បីឈ្មោះ
- របាយការណ៍ប្រចាំឆ្នាំ
- សុន្ទរកថាសាធារណៈរបស់នាយកប្រតិបត្តិក្រុមហ៊ុន
- ឯកសារដែលមានជាសាធារណៈជាមួយភ្នាក់ងាររដ្ឋាភិបាល

“យើងតាមដានបរិយាកាសប្រកួតប្រជែងរបស់យើង និងវិភាគនិន្នាការដើម្បីអភិវឌ្ឍអាជីវកម្មរបស់យើង”

ចុចទីនេះសម្រាប់ធនធានផ្ទៃក្នុង

← ត្រឡប់ទៅទំព័រមាតិកា

ការហាមឃាត់ការជួញដូរផ្ទៃក្នុង

យើងប្តេជ្ញាគ្រប់គ្រងព័ត៌មានដែលមិនមែនសាធារណៈអំពីដំណើរការហិរញ្ញវត្ថុ ឬផែនការអនាគតរបស់ក្រុមហ៊ុនដោយការសម្រេចចិត្តតែមួយគត់របស់យើង។ ប្រសិនបើព័ត៌មាននេះអាចមានឥទ្ធិពលលើតម្លៃភាគហ៊ុនរបស់យើង ឬការសម្រេចចិត្តរបស់អ្នកវិនិយោគ នោះវាអាចជា 'ព័ត៌មានផ្ទៃក្នុង'។ វាជាករណីខុសច្បាប់ក្នុងការប្រើប្រាស់ព័ត៌មានផ្ទៃក្នុងដើម្បីធ្វើការសម្រេចចិត្តអំពីការទិញ ឬលក់មូលបត្រដូចជាភាគហ៊ុនរបស់ក្រុមហ៊ុន មិនថាសម្រាប់ផលប្រយោជន៍ផ្ទាល់ខ្លួនរបស់អ្នក ឬនរណាម្នាក់ផ្សេងទៀតនោះទេ។



- **រក្សាព័ត៌មានផ្ទៃក្នុងដោយសម្ងាត់ និងគោរពតាមច្បាប់តឹងរឹងលើការចេញផ្សាយព័ត៌មាន។ សូមចងចាំថាច្បាប់ស្តីពីការជួញដូរផ្ទៃក្នុងបន្តអនុវត្តនៅពេលដែលអ្នកលែងជានិយោជិតរបស់ Imperial Brands**
- **មិនត្រូវចែករំលែកព័ត៌មានផ្ទៃក្នុងដោយគ្មានការយល់ព្រមជាមុននោះឡើយ ហើយធ្វើដូច្នេះនៅពេលដែលវាត្រូវបានទាមទារនៅក្នុងការអនុវត្តតួនាទីរបស់អ្នកប៉ុណ្ណោះ**
- **មិនត្រូវជួញដូរមូលបត្ររបស់ Imperial Brands, Logista ឬក្រុមហ៊ុនដែលបានចុះបញ្ជីផ្សេងទៀតដោយផ្អែកលើព័ត៌មានផ្ទៃក្នុងនោះទេ**
- **មិនត្រូវផ្សព្វផ្សាយព័ត៌មានមិនពិត ឬមិនត្រឹមត្រូវអំពី Imperial Brands ឬមូលបត្រដែលបានចុះបញ្ជីជាសាធារណៈផ្សេងទៀតនោះទេ**

“និយោជិតមួយចំនួននឹងមានលទ្ធភាពចូលប្រើប្រាស់ព័ត៌មានផ្ទៃក្នុងដែលមានសក្តានុពលបានច្រើនជាង ហើយត្រូវបានចាត់ទុកថាជា ‘និយោជិតផ្ទៃក្នុងរបស់ក្រុមហ៊ុន’”



ចុចទីនេះសម្រាប់ធនធានផ្ទៃក្នុង

របាយការណ៍ហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុសុក្រិត

យើងរាយការណ៍អំពីសកម្មភាពរបស់យើងដោយស្មោះត្រង់ និងត្រឹមត្រូវ និងសកម្មក្នុងការលើកកម្ពស់វប្បធម៌ដែលមិនអត់ឱនចំពោះការក្លែងបន្លំ។ ការរក្សាបាននូវកំណត់ត្រាហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុពេញលេញ និងត្រឹមត្រូវ ជួយឱ្យយើងធ្វើការសម្រេចចិត្តអាជីវកម្មកាន់តែប្រសើរឡើង បង្កើតការជឿទុកចិត្តជាមួយអ្នកពាក់ព័ន្ធខាងក្រៅ និងគាំទ្រមហិច្ឆតារបស់យើងសម្រាប់ភាពជោគជ័យរយៈពេលវែងប្រកបដោយនិរន្តរភាព។ ការក្លែងបន្លំកំណត់ត្រា ឬគណនី ឬការបំភាន់ការពិតគឺជាការក្លែងបន្លំ ហើយអាចមានផលវិបាកធ្ងន់ធ្ងរសម្រាប់អាជីវកម្មរបស់យើង និងបុគ្គលដែលពាក់ព័ន្ធ។



- **មានភាពស្មោះត្រង់ និងត្រឹមត្រូវក្នុងរបាយការណ៍ ការបង្ហាញ ការព្យាករណ៍ និងការវិភាគ**
- **មិនត្រូវរៀបចំ ឬបញ្ជូនព័ត៌មានមិនពិត ឬព័ត៌មានបំភាន់ ឬតំណាងគោលបំណងបំភាន់នៃប្រតិបត្តិការណាមួយឡើយ**
- **អនុវត្តតាមច្បាប់ទាំងអស់ លក្ខខណ្ឌតម្រូវនៃគណនេយ្យខាងក្រៅ និងនីតិវិធីរបស់ក្រុមហ៊ុនសម្រាប់ការរាយការណ៍ព័ត៌មានហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ**
- **លើកឡើងអំពីការព្រួយបារម្ភអំពីភាពត្រឹមត្រូវ ឬភាពពេញលេញនៃរបាយការណ៍ហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុ**

> **“យើងរាយការណ៍អំពីសកម្មភាពរបស់យើងដោយស្មោះត្រង់ និងត្រឹមត្រូវ និងសកម្មក្នុងការលើកកម្ពស់វប្បធម៌ដែលមិនអត់ឱនចំពោះការក្លែងបន្លំ”**

ចុចទីនេះសម្រាប់ធនធានផ្ទៃក្នុង



ការអនុលោមតាមលក្ខខណ្ឌតម្រូវនៃគយ និងពន្ធ

Imperial Brands អនុលោមតាមច្បាប់ជាតិ និងអន្តរជាតិទាំងអស់ស្តីពីការបង់ពន្ធសាជីវកម្ម និងថ្នាំជក់។ យើងមានភាពសុក្រិត និងតម្លាភាពក្នុងការបង្ហាញព័ត៌មាន និងការបញ្ជាក់របស់យើង ហើយយើងចូលរួមប្រកបដោយការស្ថាបនាជាមួយអាជ្ញាធរគយ និងពន្ធទូទាំងពិភពលោក ដើម្បីជួយប្រយុទ្ធប្រឆាំងនឹងការជួញដូរខុសច្បាប់លើផលិតផលរបស់យើង។ យើងមានគោលការណ៍ដើម្បីជៀសវាងការសម្របសម្រួលនៃការគេចពន្ធ មិនថាធ្វើឡើងដោយនិយោជិត អ្នកដែលតំណាង ឬអ្នកដែលធ្វើសកម្មភាពក្នុងនាម Imperial Brands ឬអ្នកជាប់ពន្ធផ្សេងទៀតដែលយើងធ្វើប្រតិបត្តិការនោះទេ។



- **អនុលោមតាមច្បាប់ជាតិ និងអន្តរជាតិទាំងអស់ស្តីពីពន្ធគយ ពន្ធសាជីវកម្ម និងថ្នាំជក់**
- **រាយការណ៍ពីភាពខុសគ្នានៅក្នុងផលិតផលដែលទទួលបាន ឬភាពមិនត្រឹមត្រូវនៅក្នុងដំណើរការពិនិត្យនិងកត់ត្រា ទៅកាន់អាជ្ញាធរគយដែលពាក់ព័ន្ធ**
- **មិនត្រូវយកគំរូផលិតផលតាមខ្លួននៅពេលធ្វើដំណើរសម្រាប់គោលបំណងអាជីវកម្មឡើយ**
- **ធានាថាភ្នាក់ងារ អន្តរការី និងទីប្រឹក្សាពន្ធដែលធ្វើសកម្មភាពក្នុងនាម Imperial Brands គឺស្ថិតក្រោមលក្ខខណ្ឌត្រួតពិនិត្យ និងនីតិវិធីនៃការចុះកិច្ចសន្យាសមស្រប**

> **យើងមានភាពសុក្រិត និងមានតម្លាភាពក្នុងការបង្ហាញព័ត៌មាន និងការបញ្ជាក់របស់យើង ហើយយើងចូលរួមប្រកបដោយការស្ថាបនាជាមួយអាជ្ញាធរគយ និងពន្ធទូទាំងពិភពលោក**

ចុចទីនេះសម្រាប់ធនធានផ្ទៃក្នុង យុទ្ធសាស្ត្រពន្ធ Group



← ត្រឡប់ទៅទំព័រមាតិកា

ការអនុលោមតាមទណ្ឌកម្ម និងការរឹតបន្តឹងពាណិជ្ជកម្ម

យើងប្តេជ្ញាអនុវត្តតាមទណ្ឌកម្មអន្តរជាតិ និងការរឹតបន្តឹងពាណិជ្ជកម្មជាសកល។ យើងរក្សានីតិវិធីដើម្បីជួយធានាថាយើងមិនចូលទៅក្នុងអាជីវកម្ម ពាណិជ្ជកម្ម ប្រតិបត្តិការហិរញ្ញវត្ថុ ឬប្រតិបត្តិការពាណិជ្ជកម្មផ្សេងទៀតជាមួយភាគីទីបី ក្រុមហ៊ុន ឬបុគ្គលដែលទទួលរងទណ្ឌកម្មដែលអាចអនុវត្តបាននោះទេ។



- **ស្វែងយល់ពីការដាក់ទណ្ឌកម្ម និងការរឹតបន្តឹងពាណិជ្ជកម្មដែលពាក់ព័ន្ធនឹងតួនាទី និងការទទួលខុសត្រូវរបស់អ្នក ហើយស្វែងរកការណែនាំពីអ្នកប្រឹក្សាផ្នែកច្បាប់ក្នុងតំបន់របស់អ្នក ឬផ្នែកច្បាប់របស់ Group ប្រសិនបើអ្នកត្រូវការជំនួយ**
- **ធ្វើអាជីវកម្មតែជាមួយភាគីទីបីដែលបានយល់ព្រម (បុគ្គល និងក្រុមហ៊ុន) ដែលស្ថិតក្រោមនីតិវិធីនៃការវាយតម្លៃដោយយកចិត្តទុកដាក់របស់យើងប៉ុណ្ណោះ**
- **មិនត្រូវទទួលយក ឬព្រងើយកន្តើយនឹងការសង្ស័យថាមានការរំលោភបំពានលើ ទណ្ឌកម្មអន្តរជាតិ ឬការរឹតបន្តឹងពាណិជ្ជកម្មណាមួយឡើយ**
- **ពិនិត្យមើលថាតើការដាក់ទណ្ឌកម្ម ឬការរឹតបន្តឹងពាណិជ្ជកម្មអនុវត្តចំពោះភាគីទីបីណាមួយ (បុគ្គល ឬក្រុមហ៊ុន) ដែលយើងធ្វើអាជីវកម្មជាមួយឬអត់ និងមិនត្រូវចូលរួមក្នុងការរៀបចំដែលបានរចនាឡើងដើម្បីគេច ឬជៀសវាងការដាក់ទណ្ឌកម្មនោះទេ**

> **“យើងប្តេជ្ញាអនុវត្តតាមទណ្ឌកម្មអន្តរជាតិ និងការរឹតបន្តឹងពាណិជ្ជកម្មនៅគ្រប់ប្រទេសដែលយើងធ្វើអាជីវកម្ម”**



ចុចទីនេះសម្រាប់ធនធានផ្ទៃក្នុង

← ត្រឡប់ទៅទំព័រមាតិកា

ការលាងលុយកខ្វក់

យើងចាត់វិធានការដើម្បីជៀសវាងការលាងលុយកខ្វក់នៅក្នុងអាជីវកម្មរបស់យើងដោយចូលរួមតែជាមួយអតិថិជន និងអ្នកចែកចាយស្របច្បាប់ប៉ុណ្ណោះ។ ការលាងលុយកខ្វក់ជារឿយៗត្រូវបានផ្សារភ្ជាប់ទៅនឹងឧក្រិដ្ឋកម្ម និងអំពើភេរវកម្មដែលមានការរៀបចំ។ វាជាទំនួលខុសត្រូវរបស់យើងក្នុងការធានាថា អង្គភាពទាំងឡាយនេះមិនប្រើប្រាស់ Imperial Brands ដើម្បីលាងលុយកខ្វក់ ឬបិទបាំងសកម្មភាព ឬអត្តសញ្ញាណរបស់ពួកគេនោះទេ។



- **ស្វែងយល់ថាតើការលាងលុយកខ្វក់ជាអ្វី និងរបៀបដែលវាអាចប៉ះពាល់ដល់ Imperial ។ រាយការណ៍ពីកង្វល់ណាមួយដែលអ្នកសង្ស័យ ឬសង្កេតឃើញ**
- **ទទួលយកតែការបង់ប្រាក់ពីអតិថិជនដែលបានយល់ព្រម អ្នកចែកចាយ និងអាជីវកម្មផ្សេងទៀត ឬបុគ្គលដែលក្រុមហ៊ុន Imperial Brands ជាធម្មតាធ្វើអាជីវកម្មជាមួយ និងដែលស្ថិតក្រោមការត្រួតពិនិត្យដោយយកចិត្តទុកដាក់**
- **ទទួលយកតែការទូទាត់ដែលទទួលបានពី ឬផ្ញើទៅគណនីធនាគារដែលជាឈ្មោះនីតិបុគ្គល ឬបុគ្គលដែលយើងធ្វើពាណិជ្ជកម្មជាមួយ**
- **មិនត្រូវព្រងើយកន្តើយដោយចេតនា ឬដោយធ្វេសប្រហែសចំពោះ 'សញ្ញាព្រមាន' ដែលបង្ហាញថាប្រតិបត្តិការហិរញ្ញវត្ថុមិនត្រឹមត្រូវអាចកំពុងកើតឡើង ដូចជាប្រតិបត្តិការសាច់ប្រាក់ចំនួនច្រើន ប្រតិបត្តិការនៅក្រៅប្រទេស ឬការប្រើប្រាស់អង្គភាពអនាមិក**



“យើងចាត់វិធានការដើម្បីជៀសវាងការលាងលុយកខ្វក់នៅក្នុងអាជីវកម្មរបស់យើងដោយការចូលរួមតែជាមួយអតិថិជន និងអ្នកចែកចាយស្របច្បាប់ប៉ុណ្ណោះ”

ចុចទីនេះសម្រាប់ធនធានផ្ទៃក្នុង

← ត្រឡប់ទៅទំព័រមាតិកា

ទំនាក់ទំនងអ្នកផ្គត់ផ្គង់ដែលជឿទុកចិត្ត

ដើម្បីទទួលបានជោគជ័យ យើងពឹងផ្អែកលើទំនាក់ទំនងដែលគួរជឿជាក់ និងគួរឱ្យទុកចិត្តជាមួយអ្នកផ្គត់ផ្គង់ និងសមត្ថភាពរបស់យើងក្នុងការបង្កើនតម្លៃ និងកាត់បន្ថយហានិភ័យនៅពេលធ្វើការជាមួយពួកគេ។ យើងធ្វើសកម្មភាពលទ្ធកម្មរបស់យើងដោយយុត្តិធម៌ តម្លាភាព និងមានវិជ្ជាជីវៈ ហើយយើងព្យាយាមជ្រើសរើស និងធ្វើអាជីវកម្មជាមួយអ្នកផ្គត់ផ្គង់ ដែលប្រព្រឹត្តដោយក្រមសីលធម៌ និងការទទួលខុសត្រូវ។



- **អនុវត្តតាមដំណើរការលទ្ធកម្មដែលបានបង្កើតឡើង រួមទាំងការអនុវត្តការស៊ើបអង្កេតយ៉ាងល្អិតល្អន់តាមតម្រូវការ**
- **មិនត្រូវធ្វើការសន្យាជាលាយលក្ខណ៍អក្សរ ឬពាក្យសំដីចំពោះអ្នកផ្គត់ផ្គង់នោះទេ លុះត្រាតែអ្នកមានសិទ្ធិធ្វើដូច្នេះ**
- **ត្រូវប្រាកដថាអ្នកផ្គត់ផ្គង់ទទួលបាន ក្រមប្រតិបត្តិរបស់អ្នកផ្គត់ផ្គង់ របស់យើង ដែលបង្ហាញពីការរំពឹងទុករបស់យើងចំពោះក្រមសីលធម៌ និងការទទួលខុសត្រូវ**
- **មិនត្រូវទទួលយក ឬព្រងើយកន្តើយចំពោះសកម្មភាពអ្នកផ្គត់ផ្គង់ដែលអាចបំពានលើក្រម ឬស្តង់ដាររបស់យើងនោះទេ។ រាយការណ៍ពីកង្វល់ណាមួយទៅកាន់ក្រុមលទ្ធកម្ម ឬតាមរយៈ ឆានែលSpeaking Up**

ដើម្បីទទួលបានជោគជ័យ យើងពឹងផ្អែកលើទំនាក់ទំនងដែលគួរជឿជាក់ និងគួរឱ្យទុកចិត្តជាមួយអ្នកផ្គត់ផ្គង់

សូមចុចទីនេះសម្រាប់ធនធានផ្ទៃក្នុង   ក្រមប្រតិបត្តិរបស់អ្នកផ្គត់ផ្គង់

ការចូលរួមជាមួយរដ្ឋាភិបាល និងស្ថាប័ននយោបាយ

យើងចូលរួមជាមួយរដ្ឋាភិបាល គណបក្សនយោបាយ និងបេក្ខជនក្នុងវិធីដូចគ្នាដែលយើងចូលរួមជាមួយអ្នកពាក់ព័ន្ធខាងក្រៅជាច្រើនទៀត៖ ដោយបើកចំហ មានសីលធម៌ និងដើម្បីតែគាំទ្រដល់ការសម្រេចគោលបំណងអាជីវកម្មស្របច្បាប់របស់យើងតែមួយគត់។ ការប្រព្រឹត្តមិនត្រឹមត្រូវដែលពាក់ព័ន្ធនឹងមន្ត្រីរដ្ឋាភិបាល ឬមន្ត្រីសាធារណៈអាចបង្កហានិភ័យដល់កេរ្តិ៍ឈ្មោះ និងផ្លូវច្បាប់យ៉ាងធ្ងន់ធ្ងរសម្រាប់ Imperial Brands ។

នៅក្នុងកាលៈទេសៈខ្លះ ការចូលរួមរបស់យើងអាចរួមបញ្ចូលការរួមចំណែកផ្នែកនយោបាយ។ រាល់ការរួមចំណែកបែបនេះត្រូវតែស្ថិតនៅក្រោមកម្រិតខ្ពស់បំផុតនៃតម្លាភាព និងគណនេយ្យភាព ហើយត្រូវបានអនុម័តដោយអនុលោមតាមការណែនាំរបស់ក្រុមហ៊ុន។



- **ត្រូវប្រាកដថាអន្តរកម្មរបស់រដ្ឋាភិបាលត្រូវបានអនុវត្តដោយ ឬជាមួយសហសេវិកដែលមានការបណ្តុះបណ្តាល ឬអ្នកប្រឹក្សានយោបាយដែលត្រូវបានយល់ព្រមជាផ្លូវការជាមុនប៉ុណ្ណោះ។**
- **អនុវត្តតាមការណែនាំ និងគោលនយោបាយរបស់ក្រុមហ៊ុន នៅពេលមានទំនាក់ទំនងជាមួយគណបក្សនយោបាយ និងបេក្ខជននយោបាយ**
- **មិនត្រូវធ្វើការទូទាត់សម្រាប់ការចូលប្រើ ឬមានឥទ្ធិពលជាមួយនិយតករ ឬក្រុមបញ្ចុះបញ្ចូលពិសេស**
- **ស្វែងរកមតិចូលរួមផ្លូវច្បាប់មុនពេលមានការចូលរួមក្នុងឧស្សាហកម្មរួមជាមួយរដ្ឋាភិបាល ឬនិយតករ**

ចុចទីនេះសម្រាប់ធនធានផ្ទៃក្នុង

> **ការប្រព្រឹត្តមិនត្រឹមត្រូវដែលពាក់ព័ន្ធនឹងមន្ត្រីរដ្ឋាភិបាល ឬមន្ត្រីសាធារណៈ អាចបង្កហានិភ័យកេរ្តិ៍ឈ្មោះ និងផ្លូវច្បាប់យ៉ាងធ្ងន់ធ្ងរសម្រាប់ Imperial Brands**



← ត្រឡប់ទៅទំព័រមាតិកា

បរិស្ថាន និងសង្គម

យើងធ្វើប្រតិបត្តិការក្នុងលក្ខណៈដែលគោរពដល់បរិស្ថាន និងសិទ្ធិរបស់សហគមន៍ដែលយើងប្រតិបត្តិការ។ យើងប្តេជ្ញាកាត់បន្ថយផលប៉ះពាល់បរិស្ថានរបស់យើងឱ្យតិចបំផុត ហើយខិតខំរួមចំណែកជាវិជ្ជមានដល់សង្គមតាមរយៈការជួយដល់ជីវភាពរស់នៅរបស់មនុស្សដែលចូលរួមជាមួយអាជីវកម្មរបស់យើង។

43 ការការពារបរិស្ថានធម្មជាតិ

44 ការចូលរួមចំណែកក្នុងកម្មវិធីសប្បុរសធម៌ និងការងារស្ម័គ្រចិត្ត

“យើងប្តេជ្ញាកាត់បន្ថយផលប៉ះពាល់បរិស្ថានរបស់យើង និងខិតខំរួមចំណែកជាវិជ្ជមានដល់សង្គម”

← ត្រឡប់ទៅទំព័រមាតិកា

ការការពារបរិស្ថានធម្មជាតិ

ការការពារបរិស្ថានធម្មជាតិគឺមានសារៈសំខាន់សម្រាប់និរន្តរភាពនៃភពផែនដីរបស់យើង និងសុខុមាលភាពរបស់មនុស្សជំនាន់ក្រោយ។ យើងប្តេជ្ញាកាត់បន្ថយផលប៉ះពាល់បរិស្ថានរបស់យើងដោយការទទួលខុសត្រូវលើការប្រើប្រាស់ធនធាន កាត់បន្ថយការបំពុល និងកាកសំណល់ និងការអភិរក្សជីវចម្រុះ។ លើសពីនេះទៀត ស្របជាមួយនឹងមហិច្ឆតារបស់យើងក្នុងការក្លាយជា Net Zero នៅឆ្នាំ 2040 យើងក៏នឹងកាត់បន្ថយការបញ្ចេញកាបូន និងលើកកម្ពស់ថាមពលកកើតឡើងវិញផងដែរ។ ការគ្រប់គ្រងប្រកបដោយទំនួលខុសត្រូវពាក់ព័ន្ធនឹងការអប់រំ និងការផ្តល់សិទ្ធិអំណាចដល់មនុស្សឱ្យធ្វើការជ្រើសរើសត្រឹមត្រូវ គាំទ្រវប្បធម៌នៃការថែរក្សាបរិស្ថានរបស់យើង។



- **កាត់បន្ថយការប្រើប្រាស់ថាមពលតាមរយៈការអភិរក្ស និងប្រសិទ្ធភាពថាមពល និងលើកកម្ពស់ថាមពលកកើតឡើងវិញ ជាលទ្ធផលវានឹងកាត់បន្ថយការបញ្ចេញកាបូន**
- **កាត់បន្ថយកាកសំណល់នៅទីកន្លែងផ្ទាល់ និងអនុវត្តការកែច្នៃឡើងវិញ**
- **នៅតំបន់ខ្វះខាតទឹក ត្រូវប្រើប្រាស់ទឹកដោយការទទួលខុសត្រូវ**
- **ការពារបរិស្ថានធម្មជាតិ និងលើកកម្ពស់ជីវចម្រុះ**

> **“យើងទទួលស្គាល់ពីសារៈសំខាន់នៃការថែរក្សាភពផែនដីរបស់យើងសម្រាប់មនុស្សជំនាន់ក្រោយ ហើយខិតខំធ្វើជាដៃគូដែលមានទំនួលខុសត្រូវ”**

សូមចុចទីនេះសម្រាប់ធនធានផ្ទៃក្នុង   គោលការណ៍បរិស្ថាន Group
យុទ្ធសាស្រ្តមនុស្ស និងភពផែនដី   សេចក្តីសង្ខេបនៃការអនុវត្ត ESG

← ត្រឡប់ទៅទំព័រមាតិកា

ចូលរួមចំណែកក្នុងកម្មវិធីសប្បុរសធម៌ និងការងារស្ម័គ្រចិត្ត

យើងប្តេជ្ញាក្នុងការរួមចំណែកជាវិជ្ជមានដល់សហគមន៍ដែលយើងប្រតិបត្តិការជាមួយ។ វាល្អសម្រាប់ការចូលរួមរបស់និយោជិត ទំនាក់ទំនងអាជីវកម្ម និងកេរ្តិ៍ឈ្មោះក្រុមហ៊ុនរបស់យើង និងជាផ្នែកសំខាន់នៃតួនាទីដ៏ធំទូលាយរបស់យើងនៅក្នុងសង្គម។ សកម្មភាពសប្បុរសធម៌របស់យើងគឺស្របតាមក្រុមហ៊ុន**យុទ្ធសាស្ត្រមនុស្ស និងភពផែនដី**។

ការអនុញ្ញាតឱ្យនិយោជិតគាំទ្រសហគមន៍របស់ពួកគេជាផ្នែកនៃការងាររបស់ពួកគេអាចជួយដល់សុខុមាលភាពតាមរយៈការបង្កើនបទពិសោធន៍ ការតបស្នងត្រលប់មកវិញ និងដើម្បីឱ្យមានការយល់ឃើញកាន់តែទូលំទូលាយអំពីកាលៈទេសៈរបស់អ្នកដទៃ។



- **ផ្តោតលើការគាំទ្រសហគមន៍លើគម្រោងដែលស្របតាមយុទ្ធសាស្ត្រមនុស្ស និងភពផែនដីរបស់យើង និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ សំដៅលើកកម្ពស់ជីវភាពរស់នៅរបស់មនុស្ស**
- **ធ្វើការបរិច្ចាគសាជីវកម្មសម្រាប់តែអង្គការសប្បុរសធម៌ដែលបានចុះបញ្ជីជាផ្លូវការ និងស្របច្បាប់ប៉ុណ្ណោះ**
- **មិនត្រូវប្រើការរួមចំណែកសប្បុរសធម៌ ឬការវិនិយោគសហគមន៍ ដើម្បីផ្សព្វផ្សាយផលិតផល ឬម៉ាកយីហោរបស់ Imperial Brands នោះទេ**
- **ជៀសវាងការចូលរួមវិភាគទានទាក់ទងនឹងកុមារ ជំងឺដែលទាក់ទងនឹងការជក់បារី សិល្បៈ និងកីឡា។ សកម្មភាពដែលផ្តោតលើការការពារពលកម្មកុមារគឺអាចទទួលយកបាន។ សូមមើលការណែនាំក្នុងតំបន់**

ចុចទីនេះសម្រាប់ធនធានផ្ទៃក្នុង យុទ្ធសាស្ត្រមនុស្ស និងភពផែនដី

កម្មវិធីភាពជាដៃគូ Leaf របស់យើង

កម្មវិធីភាពជាដៃគូ Leaf របស់យើងគាំទ្រដល់មហិច្ឆតាជីវភាព និងសុខុមាលភាពកសិកររបស់យើង និងផ្តល់មូលនិធិដល់គម្រោងដែលទាក់ទងនឹងនិរន្តរភាពហិរញ្ញវត្ថុ កសិកម្មប្រកបដោយនិរន្តរភាព និងលទ្ធភាពទទួលបានតម្រូវការជាមូលដ្ឋានដូចជាការអប់រំ និងទឹកស្អាត។ សកម្មភាពដែលធ្វើឡើងតាមរយៈកម្មវិធីនេះមិនត្រូវបានរាប់បញ្ចូលពីគោលការណ៍ណែនាំទាំងនេះទេ។

សទ្ទានុក្រម



ការស៊ើបអង្កេតដោយយកចិត្តទុកដាក់

ដំណើរការដែលពាក់ព័ន្ធនឹងការត្រួតពិនិត្យហានិភ័យ និងការអនុលោមឬសវនកម្ម ដើម្បីផ្ទៀងផ្ទាត់ការពិត និងព័ត៌មានអំពីភាគីទីបី។

ការរើសអើង

ការអនុវត្តការប្រព្រឹត្តិដែលមិនស្មើភាពចំពោះបុគ្គលណាម្នាក់ ដោយផ្អែកលើយេនឌ័រ ពណ៌សម្បុរ ជាតិសាសន៍ ពិការភាព ឬមូលដ្ឋានណាមួយផ្សេងទៀតដែលមិនទាក់ទងនឹងការអនុវត្ត ឬសមត្ថភាពក្នុងការអនុវត្តទំនួលខុសត្រូវរបស់ពួកគេ។

ការទូទាត់សម្របសម្រួល

ការទូទាត់ជូនមន្ត្រីរដ្ឋាភិបាល ដើម្បីពន្លឿនសកម្មភាពដែលមន្ត្រីគួរអនុវត្តតាមទម្លាប់។

ការក្លែងបន្លំ

ការបោកបញ្ឆោតដោយចេតនាក្នុងគោលបំណងដើម្បីរកផលប្រយោជន៍ផ្ទាល់ខ្លួនដោយទុច្ចរិត ផលប្រយោជន៍សម្រាប់ Group ឬផលប្រយោជន៍សម្រាប់បុគ្គល ឬក្រុមហ៊ុនផ្សេងទៀតដែលជាការចំណាយរបស់ Group ។ អាចរួមបញ្ចូលការបំភាន់ព័ត៌មានហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុ ការមិនបញ្ចេញព័ត៌មាន ឬការយកទ្រព្យសម្បត្តិធ្វើជារបស់ខ្លួន ក្នុងចំណោមបទឧក្រិដ្ឋផ្សេងៗទៀត។

ការបៀតបៀន

ទម្រង់នៃអាកប្បកិរិយាមិនមានការស្វាគមន៍ ជាពាក្យសំដី មិនមែនពាក្យសំដី ឬកាយវិការណាមួយដែលបំពានសេចក្ដីថ្លៃថ្នូររបស់បុគ្គលផ្សេងទៀត និង/ឬបង្កើតបរិយាកាសការងារដែលគួរឱ្យភ័យខ្លាច អរិភាព ការបន្ទាបបន្ថោក បង្កការអាម៉ាស់ឬដែលប្រមាថ។

ការជួញដូរខុសច្បាប់

ការចែកចាយ ឬលក់ផលិតផលដែលគ្មានការអនុញ្ញាតនៅខាងក្រៅទីផ្សារភូមិសាស្ត្រ ឬបណ្ដាញចែកចាយរបស់ពួកគេ។ ឧទាហរណ៍ ផលិតផលក្លែងក្លាយ ឬការរត់ពន្ធទំនិញ។

ការជួញដូរផ្ទៃក្នុង

ការប្រើប្រាស់ព័ត៌មានមិនមែនសាធារណៈអំពីប្រតិបត្តិការហិរញ្ញវត្ថុ ឬផែនការអនាគតរបស់ក្រុមហ៊ុនដើម្បីធ្វើការសម្រេចចិត្តលើការទិញ ឬលក់មូលបត្រ ដូចជាភាគហ៊ុនរបស់ក្រុមហ៊ុន។

ការលាងលុយកខ្វក់

ការអនុវត្តប្រតិបត្តិការដើម្បីបំប្លែងទ្រព្យសម្បត្តិដែលទទួលបានដោយខុសច្បាប់ទៅជាទ្រព្យសម្បត្តិដែលហាក់ដូចជាស្របច្បាប់។

សទ្ទានុក្រម

ការបោកបន្លំតាមអ៊ីនធឺណិត
ការប៉ុនប៉ងដើម្បីទទួលព័ត៌មានដូចជា ឈ្មោះអ្នកប្រើប្រាស់ ពាក្យសម្ងាត់ ព័ត៌មានការប្រកួតប្រជែង ឬព័ត៌មានផ្ទាល់ខ្លួន និង/ឬប្រព័ន្ធធនាគារ ឬប្រព័ន្ធចូលប្រើ តាមរយៈការប្រើអ៊ីមែល សារ គេហទំព័រ ឬការហៅទូរសព្ទ ដែលតែងតែធ្វើពុធជានរណាម្នាក់ដែលចាត់ទុកថាគួរឱ្យទុកចិត្ត។

ការចូលរួមចំណែកនយោបាយ
ទម្រង់ផ្សេងៗនៃការទទួលអំណោយ ដូចជាសាច់ប្រាក់ សេវាកម្ម ឬអ្វីផ្សេងទៀតដែលមានតម្លៃពីបុគ្គល ឬអង្គការ ដើម្បីគាំទ្រគណបក្សនយោបាយ អ្នកនយោបាយ ឬបេក្ខជននយោបាយណាមួយ។

ការសងសឹក
ការប្រព្រឹត្តិតចំពោះដោយមិនស្មើភាព ឬទម្រង់នៃការបំបាក់ណាមួយ ដូចជាការទម្លាក់តំណែង ការបន្ថយប្រាក់បៀវត្សរ៍ ឬលក្ខខណ្ឌការងារ ឬការបណ្ដេញចេញពីការងារ ទៅលើបុគ្គលម្នាក់ទៀត ដោយសារការរាយការណ៍ថាមានការសង្ស័យថាមានកំហុស ឬការប្រព្រឹត្តខុស។

ការគេចពន្ធឬការសម្របសម្រួលការគេចពន្ធ
រាល់សកម្មភាពរបស់ក្រុមហ៊ុន ឬអ្នកពាក់ព័ន្ធណាមួយ ដើម្បីបោកបន្លំចំណូលសាធារណៈដោយចេតនា ឬបន្លំគេចពន្ធ។

កម្មសិទ្ធិបញ្ញា
ទ្រព្យសម្បត្តិដែលត្រូវបានការពារដោយស្របច្បាប់ ដូចជាពាណិជ្ជសញ្ញា សិទ្ធិរចនា ប៉ាតង់ និងការរក្សាសិទ្ធិ ដែលរារាំងអ្នកដទៃពីការចំណេញពីម៉ាក និងការច្នៃប្រឌិតរបស់យើង។

ច្បាប់ប្រកួតប្រជែង
ច្បាប់ដែលបានរចនាឡើងដើម្បីលើកទឹកចិត្តទីផ្សារសេរី និងការពារអ្នកប្រើប្រាស់ និងអាជីវកម្មដោយធ្វើនិយតកម្មទំនាក់ទំនងរវាងដៃគូប្រកួតប្រជែង អតិថិជន អ្នកចែកចាយ និងភាគីទីបីផ្សេងទៀត ព្រមទាំងធ្វើសកម្មភាពនៅក្នុងបរិយាកាសដែល Imperial Brands មានអំណាចទីផ្សារយ៉ាងសំខាន់។

ដៃគូអាជីវកម្មខាងក្រៅ
បុគ្គល ឬអង្គការដែលចូលរួមក្នុងទំនាក់ទំនងពាណិជ្ជកម្មជាមួយ Imperial Brands ដូចជាអតិថិជន អ្នកផ្គត់ផ្គង់ អ្នកចែកចាយ ឬភ្នាក់ងារ។

ដៃគូអាជីវកម្ម People & Culture (P&C)
សហសេវិក Imperial ដែលចាប់ដៃគូជាមួយក្រុមក្នុងអាជីវកម្ម។

ទំនាស់ផលប្រយោជន៍
ស្ថានភាពដែលផលប្រយោជន៍ឯកជន ឬផលប្រយោជន៍ផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់មានសក្ដានុពលក្នុងការជះឥទ្ធិពលលើរបៀបដែលពួកគេបំពេញកាតព្វកិច្ចនៃវិជ្ជាជីវៈរបស់ខ្លួន។ ទំនាស់ផលប្រយោជន៍អាចពាក់ព័ន្ធនឹងទិដ្ឋភាពហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុ។

ទាសភាពទំនើប
ការជ្រើសរើស ការផ្លាស់ទី ការលាក់កំបាំង ឬទទួលបុគ្គលតាមរយៈការប្រើប្រាស់កម្លាំង ការបង្ខិតបង្ខំ ការរំលោភលើភាពងាយរងគ្រោះ ការបោកប្រាស់ ឬមធ្យោបាយផ្សេងទៀតសម្រាប់គោលបំណងនៃការកេងប្រវ័ញ្ច។ វារួមបញ្ចូលទាំងពលកម្មដោយបង្ខំ និង/ឬជួញដូរ ពលកម្មកុមារ ការកេងប្រវ័ញ្ចផ្លូវភេទ ការរៀបការដោយបង្ខំ ការបង្ខំឱ្យធ្វើការដើម្បីដោះបំណុល។

សទ្ទានុក្រម

ទណ្ឌកម្ម

វិធានការដាក់ដោយរដ្ឋាភិបាល និងស្ថាប័នអន្តរជាតិ ដើម្បីរឹតបន្តឹងការទំនាក់ទំនងជាមួយប្រទេស អង្គភាព និង/ឬបុគ្គលមួយចំនួន។ នេះអាចរួមបញ្ចូលការរឹតបន្តឹងសេដ្ឋកិច្ច ការរឹតបន្តឹងពាណិជ្ជកម្ម ការដាក់ទណ្ឌកម្មហិរញ្ញវត្ថុ និងការហាមឃាត់ការធ្វើដំណើរ។

ព័ត៌មានផ្ទាល់ខ្លួន

ព័ត៌មានទាក់ទងនឹងបុគ្គល ដូចជាឈ្មោះ ព័ត៌មានលម្អិតទំនាក់ទំនង តំណែងការងារ កន្លែងកំណើត ឬថ្ងៃខែឆ្នាំកំណើត។

ព័ត៌មានសម្ងាត់

ព័ត៌មានសម្ងាត់អាចរួមបញ្ចូលការអភិវឌ្ឍផលិតផល និងដំណើរការ ការលក់ ការធ្វើទីផ្សារ និងទិន្នន័យហិរញ្ញវត្ថុ ផែនការអាជីវកម្ម ការផ្លាស់ប្តូរអ្នកគ្រប់គ្រងជាន់ខ្ពស់ និងព័ត៌មានអំពីការទិញ និងការរួមបញ្ចូលគ្នា។ ព័ត៌មានផ្ទាល់ខ្លួនក៏ត្រូវបានចាត់ទុកថាជាការសម្ងាត់ផងដែរ។

មន្ត្រីសាធារណៈ

បុគ្គលដែលកាន់មុខតំណែងនីតិបញ្ញត្តិ រដ្ឋបាល ឬតុលាការគ្រប់ប្រភេទ ទោះជាត្រូវបានតែងតាំង ឬជាប់ឆ្នោតនៅក្នុងស្ថាប័នគ្រប់គ្រងដោយរដ្ឋក៏ដោយ។

សំណូក

ការលើកទឹកចិត្ត ឬរង្វាន់ដែលផ្តល់ជូន បានសន្យា ឬផ្តល់ឱ្យ ដើម្បីទទួលបានអត្ថប្រយោជន៍ពាណិជ្ជកម្ម កិច្ចសន្យា ឬអត្ថប្រយោជន៍ផ្ទាល់ខ្លួនណាមួយ។

អំពើពុករលួយ

អាកប្បកិរិយាមិនស្មោះត្រង់ និងក្លែងបន្លំរបស់អ្នកមានអំណាច ដែលជារឿយៗពាក់ព័ន្ធនឹងការរំលោភលើការប្រើអំណាចសាធារណៈឬឯកជនដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន។